វិន័យបណ្ឌិតោ ភិក្ខុ ឡ៉ាង-ខាត់

# វប្បធម៌-អរិយធម៌ខ្មែរ-ឥណ្ឌា

ភ្នំពេញ

ការផ្សាយរបស់ពុទ្ធិកសិក្សា

ព.ស. ២៥១៣ គ.ស. ១៩៧០

# ពាក្យនាំ

សៀវភៅនេះ កើតឡើងដោយមានគំនិតថា : "អាយ៌ធម៌ខ្មែរ" ដូចម្តេច ? តាំងពីនោះមក ខ្ញុំក៏បានត្រិះរិះពិចារណាឃើញថា "អាយ៌ធម៌ខ្មែរ" របស់យើង មានហើយពីសម័យព្រេងនាយ ។ នៅផែនដីសុវណ្ណភូមិ ប្រទេសខ្មែរជាប្រទេសបរមបុរាណ មានវប្ប[illegible]ជាងប្រទេសស្រុកសៀម ។ សំរាប់ន័យនេះ អ្នកនិពន្ធ បូទ្រា មូ.តែរ (បូ មុក-តែរ) ថាបង្កើនអាយ៌ធម៌ខ្មែរ ។ តែតាមឃើញនេះ មានការលាយអាយ៌ធម៌លទ្ធិព្រាហ្មណ៍ និងពុទ្ធសាសនា ដែលផ្សាយចេញមកពីប្រទេសទន្លេគង្គា ។

ដូច្នេះ ដើម្បីឲ្យយល់លទ្ធិសាសនាព្រាហ្មណ៍ និងពុទ្ធ-សាសនា ត្រូវមើលប្រទេសឥណ្ឌា ជាប្រទេសនៅទន្លេគង្គា ។ ទឹកដីឥណ្ឌាដូចម្តេច បានជាកើតលទ្ធិសាសនាព្រាហ្មណ៍មុនលទ្ធិហិណ្ឌូព្រមទាំងពុទ្ធសាសនា ? ។ បើយើងនិយាយថា ប្រ-ទេសកម្ពុជាជាកូនទន្លេមេគង្គ យើងក៏អាចនិយាយថា ប្រទេសឥណ្ឌាជាកូនទន្លេគង្គាដែរ គឺទឹកដីប្រទេសទន្លេគង្គានេះហើយ

ដែលនាំឲ្យកើតលទ្ធិព្រាហ្មណ៍ និងពុទ្ធសាសនាឡើង ។

ខ្ញុំដើររកកាព្យធម៌ខ្មែរ តាមទំនងនេះ ។ ខ្ញុំបានឃើញខ្លះ ហើយប្រមូលយកមកចុះក្នុងសៀវភៅនេះ មិនមែនគ្រប់គ្រាន់ទេ នៅច្រើនណាស់ ដែលខ្ញុំប្រុងនឹងប្រមូលយកមកចងក្រងជាមួយគ្នាក្នុងពេលទៅមុខ ទុកសម្រាប់ការសិក្សាវប្ប-ធម៌ខ្មែរនិងកាព្យធម៌ខ្មែរតទៅ ។

ខ្ញុំសុំអរគុណ យ៉ាងក្រៃលែងទុកក្នុងទីនេះផងចំពោះលោក ញូក-សឿង ដែលលោកបានជួយពិនិត្យកែប្រែតម្រូវ ដោយយកចិត្តទុកដាក់ក្នុងការបោះពុម្ពសៀវភៅនេះ ។

មួយទៀត ការដើម, ការធ្វើមុនដំបូង តែងមានការខ្វះមិនសព្វគ្រប់ មិនសមរម្យ មិនពេញលេញស្រួល មិនគាប់ចិត្តគក់ទុស្សត្តាំត្តង, ទាំងអស់នេះបើមាន សូមអភ័យទោស ហើយសូមជួយបំភ្លឺឲ្យផង ។ ខ្ញុំសូមអរគុណជូន ទុកក្នុងទីនេះផង ។

[illegible] ១៩៦៨

[illegible] ខ-ខាត់

## ជំពូកទី ១

---

# ឥណ្ឌាបូរាណ

ដើមឡើយ ប្រទេសខ្មែរបានស្គាល់ប្រទេសឥណ្ឌានេះ ជា ស្រុកកុលិង (កលិង្គ) ដែលជារដ្ឋមួយនៅខាងទក្ខិណាបថ សព្វថ្ងៃហៅ ឧរិស្សា (Orissa) ឬ ជម្ពូទ្វីប ឬក៏ មជ្ឈិម-ប្រទេស ពុំនោះទា មធ្យមប្រទេស តែក្នុងបច្ចុប្បន្នកាលនេះ បានស្គាល់ថា "ប្រទេសឥណ្ឌា" ហើយ ។ សមញ្ញាថា "ឥណ្ឌា" នេះជានាមប្ដូរការ ក្នុងប្រទេស ជាភាសាហិណ្ឌីថា "ភារ័ត" ។ កាលពីព្រេងនាយ គេបានឲ្យនាមបញ្ញត្តិប្រទេសនេះថា " ភារ័ត វស៌ៈ " ( ភារតៈ វស៌ ), ភារត-ខណ្ឌ

ឬកុមារិកា-ខណ្ឌ តែនាមនេះ បានត្រឹមតែភូមិភាគមួយចំណែក

នៃប្រទេស ដែលមានមហានទីដ៏សំខាន់ពីរគឺ សិន្ធុ និង

គង្គា (Sindhu-Gangà) តែប៉ុណ្ណោះទេ ។ ឯនាមជម្ពូទ្វីប

“កោះមានដើមជម្ពូជាគោលចារិក” នេះ ក៏ជានាមពីព្រេង

នាយដែរ តែបានដល់ប្រទេសឥណ្ឌា ដែលជាអត្តភាព (Entité)

នៃភូមិសាស្ត្រប្រទេសនេះ ។

ប្រទេសឥណ្ឌានេះ មាននាមផ្សេងៗ គ្នាទៅទៀត ដូច

ភាសាអ៊ូរ្ឌូថា “ហិន្ទូស្ថាន” (Hindosthan) ហើយជា

ភាសាហិណ្ឌី “ហិណ្ឌូស្ថាន” (Hindûsthan) នាមទាំង

ពីរនេះ កាលដើម គេចោះសំដៅយកតែដែនដីខាងភាគឧត្តរ

ប៉ុណ្ណឹងទេ តែក្រោយនេះបានទៅជានាមប្រទេសឥណ្ឌាទាំងមូល

ហើយ ។ ពាក្យថា “ហិណ្ឌ” ជាភាសាពែរ្ស៊ី (Perse) បាន

សេចក្ដីថា “ទាំងអស់” ជាពាក្យដែលយាក្លាយពីពាក្យដើមថា

“សិន្ធុ” ដែលជាឈ្មោះមហានទី “សិន្ធុ” (ប.សំ.សិន្ធុ ទន្ទ៊,

សមុទ្រ) បានក្លាយតាមសូរសំឡេងភាសាពារ្សីមួយទៅទៀត ជាភាសាហ៊េរ៉េងថា "ឥណ្ឌុស" ហើយក្លាយបន្តមួយគ្រឡប់ទៀតទៅជាក្រិកថា៖ "ឥណ្ឌា" (Indie) ឡាតាំងក៏ថា "ឥណ្ឌា" (India) តែរ វិលទៅជាបារាំងសែសថា "អាំងដ៍" (Inde) ។ នោះជាប្រភព ឈ្មោះទាំងអស់នេះ គឺកើតមក ទៅលើភូមិភាគមហានទីសិន្ធុតែមួយនោះទៀត ។ រីឯភូមិភាគមហានទីសិន្ធុនេះ គេបានស្គាល់ទូទៅហើយ ព្រោះភូមិភាគនេះ គេទុកជាទ្វារចូលទៅកាន់ប្រទេសឥណ្ឌា និងជាច្រកចេញទៅកាន់លោកខាងក្រៅផងទៀត ។ ក្នុងបច្ចុប្បន្នកាល នាមបញ្ញត្តិថា "ឥណ្ឌា" (India) នេះ មិនមែនស៊ីសេចក្តីត្រឹមតែភូមិភាគឧត្តរ ដូចកាលដើមនោះឡើយ ស៊ីរហូតទៅដល់ប្រទេសឥណ្ឌាទាំងមូល ហើយជានាមផ្លូវការថែមទៀតផង ៕

បើពាក្យថា ហិណ្ឌាស្ថាន ឬ ហិណ្ឌូស្ថាន "ស្ថានឬប្រទេសនៃជនហិណ្ឌូ" ជាពាក្យដែលបានក្លាយមកពីពាក្យ

ឈ្មោះថា "សិន្ធុ" គឺយក ស > ហ (សព្ទៈ សិន្ធវស) ទៅជា ហព្ទៈ ហិណ្ឌុ តាមភាសាប៉ារសិ៍ ជាឈ្មោះប្រទេសនៃជនអារ្យ័ន (Aryan) ដែលមានក្រោងក្នុងគម្ពីរវេទ និងគម្ពីរវេន្ឌីដ័ទ (Vendidad) និងដារៈតាលិកា នៃអារ្យ័នមកពីព្រេងនាយទៀត ផង ក្រោយគ្រូភាសាដើមចុកសមថែរ គឺឲ្យទៅជាសិន្ធុស្ថាន (Sindhusthan) ស្ថាន ឬ ប្រទេសនៃជនសិន្ធុ តែការនេះជា ឥឡូវ ...និយាយតែនិតែជាទុស្សគ្គា នាមចាំងពីរនេះ សកលលោកទទួលស្គាល់ទូទៅហើយ ។

រីឯពួកបារាំងសទូទៅ ក៏បានស្គាល់ប្រទេសនេះយូរយារ ហើយ យល់ស្របគ្នាហៅថែនដីភាគក្រោមមហានទីសិន្ធុកាល ពីដើមនោះ ...ប្រទេសឥណ្ឌាហើយ ដូចសេចក្តីទៅនេះ

លោកដារយុស (Darius) ហៅថា "ហិ (ណ) ឌុស៑ (Hi(n)dus), លោក ឯឡាមិត (Elamites) ហៅថា "ហិ - ឥន៑ - ឌុ - ឥស៑ (Hi - In - du - is) លោក

ហេរូដូត (Hérodote) បានយកនាមបទនេះ មកក្រៀបធៀបថា ឈ្មោះមនុស្សថា "ឥណ្ឌូ-អ៊ី" (Indo — i), ឯលោកហានក្សត្រជាតិចិនថា "អិន-ទូ" (In-tou), ឯអ្នកដំណើរចិនគេមកទៀតហៅថា "ចិន-ទូ" (Chen-Tou < Sindhu) ឬក៏ "ទៀន-ជូវ" (Tien-Tchou) ។ រីនាមទាំងអស់នេះ គ្រាន់តែជាសូរសព្ទ ដែលអ្នកបរទេស ហៅប្រទេសឥណ្ឌា ដោយសំនៀងផ្សេងៗគ្នា តែប៉ុណ្ណោះទេ ។

ឯអ្នកប្រទេសឥណ្ឌាគឺជនហិណ្ឌូ ដោយពិសេស គឺពួកព្រាហ្មិន "ព្រាហ្មណ៍" និងពួកជេន "អ្នកកាន់សាសនាព្រះជិន:" (សាវកនិគន្ថនាដបុត្រ) ហៅដែនឥណ្ឌា ដែលជាប្រទេស ជាប់តាំងតែពីមហាបព៌តហិមាល័យរហូតទៅដល់មហាសមុទ្រថា ភារត: វស៌: (ភារត: វម៌:) គឺប្រទេសនៃព្រះបាទភារត: ដែលជាព្រះរាជាមួយព្រះអង្គ មាននាមល្បី-ល្បាញក្នុងគម្ពីរបុរាណ: ។ ឯភាគជាច្រើននៃប្រទេសឥណ្ឌានេះ

បិតនៅក្នុងពាក្យថា ភារតៈ វស៌ៈ ឬ ប្រទេសនៃព្រះបាទភារតៈដែលជានាមមានកត់ត្រាទុកមកក្នុងគម្ពីរមហាកាវ្យៈ និងគម្ពីរបុរាណៈ ឯជនគមក បាននាមថា ភារតី សន្តតិ=ពូជពង្សនៃព្រះបាទភារតៈ ដូចសេចក្ដីក្នុងគម្ពីរវិស្ណុបុរាណថា(១)

ឧត្តរំ យត្សមុទ្រស្យ ហិមាទ្រេស្ចៃវ ទក្សិណំ
វស៌ំ តទ្ភារតំ នាម ភារតី យត្រ សន្តតិ ។

ប្រែថា ប្រទេសដែលបិតនៅទិសឧត្តរនៃសមុទ្រ និងទិសទក្សិណ នៃមហាបព៌តហិមាល័យ បាននាមបញ្ញត្តិថា ភារតៈ វស៌ៈ ឯជនក្នុងប្រទេសនេះ ក៏បាននាមថា ភារតី សន្តតិ=ពូជពង្សភារតីគមក ។

គម្ពីរពុទ្ធសាសនា ហៅប្រទេសណានេះថា ជម្ពូទ្វីប ។ ឯរឿងព្រេងឆាយ មាននិទានទុកថា ជម្ពូទ្វីបនេះជាទ្វីបមួយក្នុងទ្វីបទាំងបួន ដែលមានភ្នំសិនេរុជាមជ្ឈមណ្ឌលភេ គឺ បុព្វ ឬ

---
១— 11 5-1

បុព្វវិទេហទ្វីប ឋិតនៅទិសបូព៌ា មនុស្សមុខមូល ដូចព្រះច័ន្ទពេញវង់, អបរគោយាន (គួរហៅថាអបរគោយាន) ឋិតនៅទិសបស្ចិម មនុស្សមានមុខសំប៉ែត, ឧត្តរកុរុទ្វីប ឋិតនៅទិសឧត្តរ មនុស្សមានមុខដូចខែមួយចំហៀង ឯជម្ពូទ្វីប ឋិតនៅទិសទក្សិណ មនុស្សមានមុខដូចព្រាយរទេះ ។ រីឯចំការតេះសេះនេះ អ្នកជាតុលាស្រុកហិណ្ឌូយល់ថា រូបរាងផែន-ទ្វីបមួយភាគធំផងគឺ មហាប្រថពីដ៏ធំនេះ ចែកជា ៧ ទ្វីប (៧ ឬ ៩ ប្រទេស?) ។ ឯជម្ពូទ្វីប ដែលជាភាគនៃផែនដីមួយយ៉ាងធំក្នុងចំណោមទ្វីបទាំង ៧ នេះ មានសហធាតុរួមជាមួយគ្នាដែរ ។ គម្ពីរពុទ្ធសាសនា មាននិយាយដែរថា ប្រទេសឥណ្ឌានេះ មានទ្រង់ព្រាយដូចរទេះគោ បែរមុខខាងត្បូងទៅទិសទក្សិណ មានគល់ធំនៅខាងទិសឧត្តរ ។ គម្ពីរព្រាហ្មណ៍និយាយថា ផែនដីប្រទេសឥណ្ឌានេះ មានទ្រង់ព្រាយប៉ុងចេញទៅក្រៅប្រាកដដូចស្លឹកឈើណ្ដក (ជាត្រីកោណ ឬ ជាអក្សរ

ក្រឹតផែនដី ∆ ។ អត្ថបទសាស្ត្រឥណ្ឌាបុរាណបានសរសេរ ប្រាប់ទ្រង់ទ្រាយប្រទេសឥណ្ឌាទុកថា " ប្រទេសឥណ្ឌានេះ មានទ្រង់ទ្រាយជាជ្រុង ៤ ( ចតុរស់ស្ថានសំស្មើគម ) ។ គម្ពីរ បុរាណៈ អធិប្បាយពីទ្វីបនេះជារឿងប្រតិស្សច្រើនប្រការណាស់ តែមិនយកមកធ្វើជាការមិនបាន ។ គម្ពីរពុទ្ធសាសនាបញ្ជាក់ ទៀតថា ជម្ពូទ្វីបនេះជាឈ្មោះដែនដីទ្វីបកាសុំបួយចំណែក តែ ជាងគេប្រទេសចិន ហើយគេបានប្រើពាក្យនេះដកបមកដល់ សតវត្សរ៍ទី ៣ មុនគ្រិស្តសករាជ វេទ្យយ៉ៈ ។ ជម្ពូទ្វីបលាត សន្ធឹងទៅវែងឆ្ងាយប្រមាណជាបួនម៉ឺនយោជន៍ គឺ ៤.០០០ យោជន៍ ជាសមុទ្រ, ៣.០០០ យោជន៍ ជាបព៌តហិមាល័យ ៣.០០០ យោជន៍ជាទីស្ថានមនុស្សអាស្រ័យនៅ ។

គម្ពីរនេះនិយាយថា បព៌តវៃតាឌ្យ (Vaitedliye) គឺភ្នំ វិន្ធ្យនេះជ័យ ដែលចែកប្រទេសឥណ្ឌាជាពីរផ្នែក គឺ ភាគ ឧត្តរ ហៅថា គយាវត៌ៈ ភាគទក្សិណហៅថា ទាក្សិ·

ណាត្យ: (Deksinatya) ទក្ខិណាបថ ។ មហាបព៌តហិមា-ល័យ ជាបព៌តមួយ ក្នុងជួរបព៌តទាំង ៧ ដែលជាប្រាការការពារប្រទេសឥណ្ឌាខាងជើងឧត្តរ ។

ប្រទេសឥណ្ឌានេះ បើគិតពីទឹកដីរបស់ខ្លួនតែ ៗ នោះ គេចែកជា ៤ ភាគធំ ៗ តាំងពីបុរាណកាលមកគឺ

១– ភាគបព៌តឬប្រទេសហិមពាន្តនៅទិសឧត្តរ

ហៅថា បវ៌តាស្រាយិន ( បវ៌តាស្រាយិន Parvatāçrāyin ) ដែលមានព្រំទុកក្នុងត្បូងបុកណា: តាប់ពីតំបន់ស្រែស្នាប់នៃ ទីវាលតារៃ ឬ តរក្សៃ (Terai) ទៅដល់កំពូលមហាបព៌ត ហិមាល័យ ព្រមទាំងទីឋានដែលមនុស្សអាស្រ័យនៅបាន ដូចប្រទេសកស្មីរ, កង្គ្រា (Kangra) តេហ្រ៊ី (Tehri) ជង គុមាអ៊ូន (Kumàun) នេប៉ាល, សិក្កិម (Sikkim) និង ភូតាន (Phothàn); ជាដើម ។

២– ភាគទីវាលដ៏ធំទិសឧត្តរ ចាប់ពីតំបន់ទំនាប

ធ្វើស្រែចំការបានតាមដងមហានទីសិន្ធុ និងស្ទឹងច្រើនជាដៃនៃមហានទីនេះ ព្រមទាំងកំណាត់ខ្សាច់ ថារ (Thàr) ធំល្ហះល្ហៅ នៃភូមិភាគសិន្ធុនិងរាជបុត្រស្ថានអស់នេះ រហូតទៅដល់តំបន់មានជីជាតិនៅតាមដងមហានទីគង្គានិងទន្លេជម្នា ឬ យមុនា (Jamna Yamuna) ព្រមទាំងមហានទីព្រហ្មបុត្រផង ។

## ៣. ភាគខ្ពង់រាបនៃប្រទេសឥណ្ឌាភាគកណ្តាល

គិតចំពោះតែភាគខាងត្បូង និងទក្ខិណាបថ ចាប់ពីភាគខាងត្បូងនៃទន្លេមហានទីគង្គា ជួរភ្នំបារីបាត្រ (Pàripàtra) ដីដ ព័ទ្ធភូមិភាគសំណល់ខ្ពង់រាបភ្នំវិន្ធ្យា ភាគបស្ចិម ភ្នំវិន្ធ្យាទាំងមូល តំបន់សហ្យាទ្រី (Sahyàdri) ឬឃាតភាគបស្ចិម និងតំបន់ ហទ្រូះ ឬឃាតបូព៌ ។

## ៤. ភាគមាត់សមុទ្រ

តាមទំលបង្គាដៃនេះហើយ បន្សៀតនៃទិសទក្សិណា ដែលលាតសន្ធឹងតាំងពីឃាតទៅដល់មាត់សមុទ្រ រាប់ចាប់តាំងពីកំពង់សុកស្តុមនៃខេត្តគាងគាន

(Kônkàn) ព្រមទាំងឆ្នេរម៉ាលបារ (Màlabàr) និងដីសណ្ដដី មានដីជាតិនៃស្ទឹងគោទាវេរី ក្រិស្ណានិងកាវេរីផង ។

លក្ខណៈភូមិប្រទេសឥណ្ឌា ដែលទុកជាស្ថានៃធម្មជាតិ បានតាក់តែងឡើងនេះ មិនមែនស្របទៅតាមការបែងចែកនៃអ្នកភូមិសាស្ត្រ ដែលបានធ្វើទុកជាប្រពៃណីតាំងតែពីបុរាណកាលមកនោះទេ ។ ក្នុងអក្សរសាស្ត្រឥណ្ឌាបូរាណ យើងបានឃើញលោកបែងចែកភូមិភាគប្រទេសឥណ្ឌានេះ ជា ៥ ចំណែកគឺ :

### ១– មជ្ឈដ្ឋានទំនាបសិន្ធុ-គង្គា (Indo-Gangétique)

ហៅថា មធ្យទេស (មជ្ឈទេស) តាមគម្ពីរព្រាហ្មណ៍ជាលោកសន្និដ្ឋានតាំងពីស្ទឹងសរស្វតី (សស៊ុតី, សល្វតី?) ដែលហូរកាត់តាមភូមិភាគថានេស្វរ (Thànecvar) និងបេហូវា (Péhoa) ដែលមានឈ្មោះតាំងពីបុរាណថាប្រិថុទកៈ (Prthûdaka) ឆ្ពោះទៅកាន់ក្រុង អល្លហាបាទ (ប. បយាគ, សំ. ប្រយាគ)

និងក្រុងពារាណសី ។ គម្ពីរពុទ្ធសាសនាថា ចាប់ពីស៊ីន សព្វថ្ងៃនៅក្នុងរាជមហាល (Rājmahal) ។

## ២- ភាគបស្ចិមនៃភូមិភាគខាងលើនេះ ហៅថា

ព្រហ្មាវត៌ ព្រហ្មសិទេស (ព្រហ្មឫទេស, Brahmarṣideça) ឯភូមិភាគនៃព្រៃពិតនេះទាំងអស់ មានទំហំប៉ុនគ្នាដែរ ហៅថា អារយាវត៌ ឬ អារយាវឋ ដែលមានសព្ទក្នុងវេយ្យាករណ៍ នៃបតញ្ជលិ បតញ្ជលី ប៉ុន្តែគម្ពីរធម៌សាស្ត្របាននិយាយថាក្នុង កាលនោះ ការកំណត់ទិសទាំងនេះ មានសេចក្តីទូលាយ ណាស់ ។ លោកបុរាណយកទិសដីធំទាំងអស់ ដែលនៅ ចន្លោះមហាបព៌តហិមាល័យនិងមហាបព៌តវិន្ធ្យា ព្រមទាំងទី ជាចន្លោះនៃសមុទ្រទិសបូព៌និងសមុទ្រទិសបស្ចិមទៀត ។ តាមលោក ប្រុសី (Prusii) ជាអ្នកប្រែវគ្គសាស្ត្រនៃព្រះបាទមាឡិកសង់ដ៍ មហាពជ មានសេចក្តីថា :

## ៣- ភូមិភាគឧត្តរនៃមធ្យទេស (Madhyadeça)

ឬ ស្រុកដែលនៅខាងជើងភូមិភាគប៉េហូវ៉ា (Péhoa) ហៅថា «ឧត្តរបថ» (Uttaràpath) ឬ ឧទីច្យៈ (Udicya) គឺ ភូមិភាគខាងជើងប្រទេសឥណ្ឌា ។

៤_ ភូមិភាគបស្ចិម ហៅថា «អបរន្តៈ» (Aparanta) ឬប្រតីច្យៈ (Praticya) គឺ ភូមិភាគបស្ចិមប្រទេសឥណ្ឌា ។

៥_ ភូមិភាគទក្សិណ ហៅថាទក្ខិណាបថ (Dakkhi-napath) ឬ ដេក្កង់ ឯភូមិភាគឦសានបូព៌ាដេក្កង់ នោះថា បូព៌ទេស (បូព៌ទេស) ឬ ប្រាច្យៈ (Pràcya) ។

ពាក្យថា «ឧត្តរបថ» គេហៅចំពោះតែប្រទេសណាភាគឧត្តរភ្នំវិន្ធ័យប៉ុណ្ណោះទេ ។ ឯទក្ខិណាបថ តាមគម្ពីរបុរាណ គឺគេហៅចំពោះតែប្រទេសណាទិសទក្សិណភាគលើ ដែលនៅខាងទិសឧត្តរនៃស្ទឹងក្រិស្ណាតែប៉ុណ្ណោះទេ ភូមិភាគទក្សិណទៅខាងក្រោយទៀតហៅថា «តាមីលកម» (Temila-kam) ឬតាមីលណាត (Tamilnat) «ប្រទេសតាមីល» ។

...ទេស (បូព៌ទេស) កាលនៅពីព្រេងនាយ លោករួម បញ្ចូលគ្នាហៅតែ "មជ្ឈិមប្រទេស" វៈផង គឺយក ...ដែនត្រង់អន្តរវេទី (Antaravedi) ឬ ទោ-អាប (Do-ab gangétique) តែប៉ុណ្ណោះ ។ ការចែកជា ៥ ចំណែកដូច បាននិពោលមកខាងលើនេះ តាមគម្ពីរបុរាណខ្លះ លោកបាន បន្ថែមភូមិភាគដទៃ ២ ទៀតគឺ ភូមិភាគ បរិតាក្រោយទិ ឬ ប្រទេសហេមវន្ត ឬ ហិមាចលប្រទេស ទីដ៏ខ្ពស់មហា បព៌តហិមាល័យផង ។

គម្ពីរភូមិសាស្ត្រសម័យបច្ចុប្បន្ន ចែងថា ប្រទេសឥណ្ឌា នេះ ចែកចេញជាភូមិភាគធំ ៦ ភាគគឺ

១- មជ្ឈិមជនបទ ឬមជ្ឈិមប្រទេស (មជ្ឈិមទេស ជា ពាក្យក្នុងគម្ពីរបុរាណ)

២- ហិមវន្តប្រទេស ឬ បរិតាក្រោយទិ

៣- ទក្ខិណបថ ឬ ឧទីច្យៈ

៤- ទក្ខិណាបថ ឬ ទាក្សិណាត្យៈ

៥- បុព្វន្តៈ ឬ ប្រាច្យៈ

៦- អបរន្តៈ ឬ ប្រតីច្យៈ ។

ក្នុងគម្ពីរមហាវគ្គ(១) មានសេចក្តីចែងថា មជ្ឈិមជនបទ មជ្ឈិមទេស ឬ មធ្យទេស មានព្រំប្រទល់ដូចតទៅនេះគឺ

១- ទិសបូព៌ា មាននិគមមួយឈ្មោះគជង្គលៈ ខាងនាយនិគមនេះ មាននិគមមួយទៀត ហៅថាមហាសាល ខាងនាយតទៅពីនិគមនេះ ហៅថា បច្ចន្តជនបទ ខាងអាយចូលមក ហៅថា មជ្ឈិមជនបទ;

២- ទិសអាគ្នេយ៍ មានស្ទឹងមួយឈ្មោះសល្លវតី ខាងនាយស្ទឹងនេះតទៅហៅថា បច្ចន្តជនបទ ខាងអាយចូលមក ហៅថា មជ្ឈិមជនបទ;

៣- ទិសទក្សិណ មាននិគមមួយឈ្មោះថា សេត-

---

១ ចម្មក្ខន្ធកៈ ព្រះត្រៃបិដក សៀវភៅទី ៧ ទំព័រ ២០៤ ។

កណ្ណិកៈ ខាងនិគមនេះតទៅ ហៅថា បច្ចន្តជនបទ ខាងអាយចូលមក ហៅថា មជ្ឈិមជនបទ;

៤ ទិសបច្ឆិម មានស្រុកព្រាហ្មណ៍ឈ្មោះ ថូនគ្រាម ខាងថូនគ្រាមនេះតទៅ ហៅថាបច្ចន្តជនបទ ខាងអាយចូលមក ហៅថា មជ្ឈិមជនបទ;

៥– ទិសឧត្តរ មានភ្នំឈ្មោះឧសីរធជៈ ខាងភ្នំនេះតទៅ ហៅថា បច្ចន្តជនបទ ខាងអាយភ្នំនេះចូលមក ហៅថា មជ្ឈិមជនបទ;

ព្រំប្រទល់មជ្ឈិមប្រទេសទិសបូព៌ គឺព្រំប្រទល់ប្រទេស ខណ្ឌទិសបូព៌ បានលាតទៅដល់កជង្គលៈ ឬទៅដល់តំបន់ បុណ្ឌ្រវទ៌នៈ (Pundràvardhana) ។ កាលពីសម័យក្រោយមក លោកក៏បញ្ចូលតំបន់វរេន្ទ្រៈ (Varendra) ទៀតផង ព្រោះតំបន់នេះគេយល់ថា ជាវិហារនៅភាគឧត្តរ វង្គបេង្គាល (Bengal) ។ វង្គៈជាមជ្ឈមណ្ឌលសំខាន់នៃការ

លក់ដូរទំនិញពាណិជ្ជកម្ម ។ ព្រំប្រទល់ទីបំផុតខាងទិសបស្ចិមនៃរដ្ឋវង្គៈ (បេង្គាល) គឺរដ្ឋអង្គៈនិងមគធៈ ។ តំបន់លាឡៈ (Lala) ឋិតនៅត្រង់ចន្លោះវង្គៈម្ខាងរដ្ឋកលិង្គម្ខាង ។ ក្នុងកាលតមក រដ្ឋវង្គៈបានដល់រដ្ឋបេង្គាលទាំងមូល ។ ឯក្រុងសុវណ្ណកូដ ឬ សុវណ្ណកុដ្ឋ ក៏ជាមជ្ឈមណ្ឌលនៃការលក់ដូរទំនិញពាណិជ្ជកម្មសំខាន់មួយទៀតដែរ ។ អ្នកខ្លះយល់ថា ទីក្រុងនេះ នៅក្នុងកាបរូបទេ ។ ប្រទេសសុហ្មៈ (Suhma) ក្នុងសម័យពុទ្ធសាសនា ក៏មានសេចក្តីដំណាលទុកថា អង្គព្រះសម្ពុទ្ធស្តេចទ្រង់យាងទៅដល់ដែរ ។ ក្រុងកំពង់មាត់សមុទ្រ ដែលមានឈ្មោះប្រាកដថា តាមលិត្តិ (P.Tàmelitti, S.Tàmralipti) សព្វថ្ងៃនេះ ឋិតនៅត្រើយបស្ចិម នៃស្ទឹងរូបនារាយណៈ (Rùpanàràyana) ហៅតាម្លុក (Tàmluk) នៅក្នុងតំបន់មិទ្នាបុរ (Midnapur) ។ ទីក្រុងវឌ៌មានៈ គេយល់ថាជា ក្រុងពុរេឌ្វន (Burdwan) សព្វថ្ងៃនេះ ។ ជបេះ និងម

គជង្គលៈ បុគៀ-ជូ-ហោះ-ទី-ឡូ នៃលោកហ៊ាន-ត្សាង(1) ជាព្រំប្រទល់ទិសបស្ចិមនៃបុរ្វទេស (Purvadeça) តែទីនេះប្រហែលជានៅត្រង់តំបន់រាជមហ័ល (Ràjmahal) ទេ ។

ព្រំប្រទល់មជ្ឈិមប្រទេស ទិសទក្សិណ បានដល់ព្រំប្រទល់ប្រទេសឥណ្ឌាទិសទក្សិណ ពោលគឺមាហិស្មតី ដែលគេសំដៅយកក្រុងមាន្ធាតា នៅតាមដងស្ទឹងនម៌ទា ឬ នម្មទា ទីនេះឬ ដែលជាសេតកណ្ណិកនិគម ? ឯតំបន់ស្ទឹងគោទាវរី និង នម៌ទាបិតនៅត្រង់ទក្ខិណាបថទេ ។ ស្ទឹងគា-វរីហូរចុះទៅកាន់សមុទ្រពង់គ័ល ក្រុងប្រតិស្ឋាន (Pratisthàn) សព្វថ្ងៃហៅប៉ៃថាន (Paithân) នៅតាមដងស្ទឹងគោទាវរី ទីនេះ គេទុកជាទីបំផុតខាងត្បូងនៃផ្លូវធំទិសទក្សិណ ដែលចេញមកពីក្រុងរាជគ្រឹះ ។ ក្រុងប្រតិស្ឋាន ឬ ប៉ៃឋាននេះនៅជិតក្រុងថ្មីមួយឈ្មោះបញ្ចវតី ត្រង់តំបន់នាសិក (Nàsik) ។

1 Travals of Hiouen-Tsang, vol 44, p. 402 by Samuel Beal

ទៅតាមដងស្ទឹងគោធាវរី មានអាណាចក្រ ៦ គឺរដ្ឋអស្សកៈ (AssaKa) រាជធានីឈ្មោះបោតនៈ (Potana) ឬពោទន្យៈ (Paubanya) និងរដ្ឋអឡ្យកៈ (Aalaka) ឬមូឡ្យកៈ (Mùlaka) រាជធានីឈ្មោះបតិដ្ឋាន (Patitthàn) តមក ឋិតនៅវិសុទ្ធក្រ ក្រុងតាស់បង្កិងទៅវិញ ។ កំពង់ៈកោលបដ្ដនៈ Kolapattana) ជាក្រុងកំពង់នៅឆ្នេរៈកាកោមណ្ឌែល (Coromendel Coromandalam=:ចារបណ្ឌាល) ។ ឯការ៉ែ ឬគ្ងេសល អេបអេសល និងសិទ្ធគាំងរបស់គេ ឋិតនៅប្រទេសអន្ធ្រៈ (Andhra) ។ ឯដែនដីទ្រាវិឌ (Dràvida) កប់យករដ្ឋចោឡ្យៈ រាជធានីឈ្មោះកាញ្ចីបុរី សព្វថ្ងៃហៅ កុញ្ជីវេរ៉ម (Conjeeveram) ឯរដ្ឋប៉ាណ្ឌ្យ (Pàndya) រាជធានីឈ្មោះ មធុរសុត្តបដ្ដនៈ សព្វថ្ងៃហៅ មធួរ (Madoura) រដ្ឋចេរៈ សព្វថ្ងៃហៅ កេរលា (Keralà) ។ រដ្ឋកលិង្គៈ (Kalinga) ជាអាណាចក្រមួយ រាជធានីឈ្មោះ ទន្តបុរ (Dantapur) ឋិតនៅជិតតំបន់

ឈីកាកូល Chicacole នៅឆ្នេរសមុទ្រ ពេង្គលេ ។ ក្រុងឱឌ្រៈ (Odra) និងក្រុងឧត្កលៈ (Utkala) ទាំង ២ នេះ ជាភាគផែនដី នៃដែនឱរិស្សា (Orissà) ។ ឯប្រទេសមេកលៈ (Mekala) ជាផែនដីប្រកគ្គីមួយ សព្វថ្ងៃគេហៅយកទាំងភ្នំ អមរកណ្ដកៈ (Amorakenteka) និងទីឋានដែលនៅជិតខាងទៀតផង ។

ព្រំប្រទល់មជ្ឈិមប្រទេសពាយព្យ គឺប្រទេសថូណា ទិសបស្ចិមនិងពាយព្យ បានដល់ស្រុកព្រាហ្មណ៍មួយឈ្មោះ ថូនគ្រាម តំបន់ប្រិថុទកៈ (Pṛthudaka) គឺពេហូអា (Pehoa) សព្វថ្ងៃនេះ ខាងទិសឧត្តរនិងទិសបស្ចិមទល់នឹងភ្នំបព៌តហិ-មាល័យ ទិសបស្ចិមលាតសន្ធឹងទៅដល់សមុទ្រអារ៉ាប់ ។ តំបន់ឧត្តរាបថ នៅទិសឧត្តរនៃតំបន់ អបរន្តៈ ឬ ប្រទេសថូណាទិសបស្ចិម ។ ទិសបស្ចិមនៃមជ្ឈិមជនបទ ដែលមានក្រុងកុរុក្ខេត្តមិត្តពុទ្ធសាសនានោះ លោកក៏សំដៅយកទីឋាន ប្រជុំក្រុមនទីនៃមហានទីសិន្ធុ ដែលសុទ្ធតែហូរមកពីមហាបព៌ត

ហិមាល័យ ។ ប្រទេសសំខាន់ៗ ដែលនៅក្នុងភូមិភាគឧត្តរ គន្ធារ: កម្ពោជ:, កុរុក:, យវន:, ទារទ: (Dārada) សិន្ធុ-សោវីរ: (Sindhu-Sauvira), មទ្រ:, កេកយ: (Kekaya) ទរទ: (Darada) ពព៌រ: (Barbara=Barbare) វាល្ហិក: (Valhika) ខឹងកាស្មីរ: ។ កាស្មីរ: (Kàçmira) សព្វថ្ងៃនេះ គឺរដ្ឋកាស្មីរ និងជម្ពូ (Jammù) ដែលមានក្រុងស្រីនគរជារាជធានី បំក នៅទិសបូព៌ានៃក្រុងប៉េសាវ៉រ (Peshawar) និងក្រុងរ៉ាវ-ល្ពិណ្ឌី (Rewalpindi) ។ ទីឋានរដ្ឋយវន: (Yavana) កាម្ពោជ: (Kemboja) នៅក្នុងប្រទេសអាហ្វហ្គានីស្ថាន (Alghànisthan) ។ ឯពាក្យថា សិន្ធុ ប្រហែលជាសិន្ធ (Sind) នៅសមុទ្រអារ៉ាប់ ។ សោវីរ: (Sauvira) ជារាជាណាចក្រមួយ មានក្រុងរោរុក: (Roruka) ជារាជធានី ។ ពព៌រ: (Barbara) គឺពព៌រិកុម (Barbaricum) ដែលមាន

និយាយទៅក្នុងបុរិប្ល៊ុស (Pariplus) ជាក្រុងផ្សារនៃមិន្នគរ (Minnagar) នៅឯភូមិភាគសមុទ្រអេរីត្រេ (Erythrée) ។ ឧត្បលាវតី (Utpalàvati) សំដៅយក បុប្ផាវតី គឺក្រុងបរ័ង្គ (Parang) និងចរស្សទ (Charssada) នៅចម្ងាយ ១៧ ម៉ៃល៍ពីភ្លៀសានខេសក់តាមដងស្ទឹងស្វាត (Swat) ។ មហានទីសិន្ធុ ស្ទឹងវិតម្សា (Vitamsà) វិតស្តា (Vitastà) ឬឈេលុម (Jhelum) និងស្ទឹងចន្ទ្រភាគា (Chandrabhàgà) សុទ្ធតែជាស្ទឹងសំខាន់ៗ នៅក្នុងតំបន់នេះ ។

ត្រង់ប្រទល់មៀងប្រទេសទិសបស្ចិម តាមគម្ពីរពុទ្ធសាសនា បានដល់ប្រទេសកណ្ដាភាគទិសបស្ចិម និងទិសឧត្តរ នៃមជ្ឈិមៈទេស ឯទិសទក្សិណានៃទក្ខិណាបថ បានដល់ឆ្នេរសមុទ្រកណ្ដាទិសបស្ចិម មានរដ្ឋភោជៈនិងរដ្ឋកស្ត្រៈ រដ្ឋទេសកា សុរាស្ត្រៈ ភគ្គកច្ឆៈ (Bhṛgukaccha) អានត៌ៈ និងអព៌ុទៈ (Anerta et Arbuda) ទាំងអស់នេះ សុទ្ធតែជាប្រទេសដែល

នៅទិសបស្ចិមប្រទេសឥណ្ឌា ។ ភ្រុគុកច្ឆ គឺព្រូច (Broach) សព្វថ្ងៃនេះ ដែលនៅក្នុងតំបន់កឋិយាវ័ទ (Kathiawad) ។ សព្វថ្ងៃនេះ រដ្ឋសុរាស្ត្រ: កប់យកកឋិយាវ័ទនិងភាគរដ្ឋគុជរ៉ាថទៀតខ្លះផង ។ មាសិក គឺតំបន់មាសិកសព្វថ្ងៃនេះ ដែលនៅតាមដងស្ទឹងនាមាដេ ទិសពាយព្យក្រុងបុំបៃ ប្រមាណជា ៧៥ ម៉ៃល៍ ។ សោវីរៈ សំដៅយកតំបន់ ឯដេរ (Eder) ដែលជាតំបន់មួយនៅក្នុងរដ្ឋគុជរ៉ាថ ក្រុងក្បាលឈូងកំបៃយ (Combay) ។

ឯប្រទេសទាំង ១៦ ដែលមានក្រាទុក ក្នុងគម្ពីរពុទ្ធ-សាសនាគឺរដ្ឋកាសី មានក្រុងពារាណសីជារាជធានី រដ្ឋកោ-សល (សំ.កោសល) មានក្រុងសាវត្ថី (សំ.ស្រាវស្តី) និងសា-កេតជារាជធានី រដ្ឋអង្គៈ មានក្រុងចម្បាជារាជធានី សព្វថ្ងៃនៅក្នុងតំបន់ភគល្ពូរ (Bhagalpur) និងម៉ុងឃឺរ (Manghyr) រដ្ឋមគធៈ សព្វថ្ងៃហៅពិហារ (Vihara) មានក្រុងរាជគ្រឹះជារាជ-

ធានី (ក្រុងបុរាណហៅគិរិព្វជ: ប្រែថា "ក្រោល" បាន សេចក្ដីថា មានបព៌តជាប្រាការព័ទ្ធជុំវិញ) ៥ ច្បូវ ដែនពិហារ ខេះ មានក្រុងបត្នៈ (បាដលីបុត្រ) ជារាជធានី នៅក្នុងតំបន់ គយា ដែនវជ្ជីមានក្រុងវេសាលីជារាជធានី សព្វថ្ងៃហៅពាសរហ៍ (Basarh) នៅក្នុងតំបន់មុសាហ្វាបុរ (Muzaffapur) ដែន មល្ល: មានក្រុងកុសិនារា ឬកុសិនគរជារាជធានី សព្វថ្ងៃហៅ កាសា (Kasia) និងបាវាបុរិ (Pàvàpuri) ដែនចេតិ ឬ ចេតិនៅតាមដងស្ទឹងយមុនា (យមុនា) ហើយលាតទៅដល់អា- ណាចក្រកុរុទៀត, ដែនវង្ស: (vamsa) ឬវត្ស: (Vatsa) មាន ក្រុងកោសម្ពី (សំ-កោសម្ពី) ជារាជធានី សព្វថ្ងៃហៅកោសម្ពនៅ ជិតក្រុងអេឡូហាបាទ ដែនកុរុ (កុរុក្សេត្រ ឬថានេស្វរ (Thaneçvar) នៅចន្លោះស្ទឹងសរស្វតី (Sarasvati) ដែលនៅទិសឧត្តរ និង ស្ទឹងទ្រឹសទ្វតី (Drsadvati) ដែលនៅទិសទក្សិណ ដែនបញ្ចាល បាន ២ គឺ ឧត្តរបញ្ចាល មានក្រុងអហិឆត្រ (Ahichatra)

ជារាជធានី សព្វថ្ងៃហៅថា រាមនគរ (Ràmnagar) នៅក្នុងតំបន់បារៃលី (Bàreilly) ។ ឯទក្ខិណបញ្ចាល មានក្រុងកាម្បិល្យៈ (Kàmpilya) ជារាជធានី សព្វថ្ងៃ ហៅកម្បិល (Kàmpil) នៅក្នុងតំបន់ហ្វារុខបាទ (Farru·khabàd) ដែលនៅក្នុងឧត្តរប្រទេស ដែនមត្ស្យៈ (Matsya) នៅក្នុងតំបន់ជ័យបុរ (Jaipur) ដែនសុរសេនៈ មានក្រុងមថុរា ជារាជធានី ដែនអស្សកៈ ឬអស្មកៈ (Açmaka) មានក្រុងបោតនៈ ឬបោតលី ជារាជធានី ដែនអវន្តិ សព្វថ្ងៃនៅក្នុងតំបន់មាល្វា (Malva) និងនិមារ (Nimar) ព្រមទាំងចំណែកដែលនៅជិតមធ្យមប្រទេសផង, ដែនគន្ធារៈ នៅក្នុងតំបន់បេសាវ៉រនិងក្រុងរាវល្ពិណ្ឌីក្នុងដីបញ្ចាប; ឯដែនកម្ពោជៈ ជាប្រទេសមួយដែលនៅចុងចុងបំផុត ខាងទិសពាយ័ព្យនៃប្រទេសឥណ្ឌា ។

# ឥណ្ឌាបច្ចុប្បន្ន

រូបសណ្ឋានដែនដីប្រទេសឥណ្ឌា សណ្ឋានទ្រង់ទ្រាយតាំងមូលនៃប្រទេសឥណ្ឌា គឺជាចតុកោណមុមមិនស្មើ ឬជាត្រីកោណពីរផ្សំគ្នាមុមជិតស្មើ មានខ្សែកក្កដនិវត្តន៍ (Tropique du cancer) ជាអ័ក្សគោលសមប្បមាណ (Axe de symétrie) និងជាជ្រុងរួមគ្នា (Côté commun) ។ ជាជ្រុងទិសបស្ចិម ឬជាជ្រុងទិសបូព៌ា ។ សមប្បមាណនៃផ្ទៃតាំងមូល មិនសមស្របគ្នាល្អទេ ព្រោះត្រីកោណទិសឧត្តរ ដែលជាប់ទៅខាងខ្ពង់រាបប៉ាមៀរ (Pamir) ទើបនៅទិស

បសុបក្សី ។ ឯភាគឧត្តរនៃខេត្ត ព្រះវិហារកំពង់ធំ

គេច្រើនឃើញមានយេដីក្ងក់ក្ងូល ប៉ុតនៅឆ្ងាយពីមាត់សមុទ្រ

ជាទីវាលដែលគេតែងមានព្រឹត្តិការណ៍ធំៗ នៃប្រវត្តិសាស្ត្រ ជាទី

បរាក្រម ដ៏ធំធេង ដែលជាកេរ៍តំណែលរបស់អ្នកស្រុកចំការ

ដែលជាប្ញសវ័ គឺវាលនេះហើយដែលជាកំណើតសាសនា

ព្រាហ្មណ៍ គឺសាសនាដែលមិនមានអ្នកណាម្នាក់ដឹងសោះថា

កើតឡើងពីរៀង ជាកេរ៍តំណែលអ្នកដែលនៅខាងដើមប្រវត្តិសាស្ត្រខេត្ត

នេះ មានមនុស្សកើតមកពីកាលណា ៗ សត្វព្រៃនេះ

ក្នុងភាគនេះនៅប្រែជាជនបទស្រ័យនៅខាប់ខាងណាស់ ៗ

ដែនដីភាគខាងត្បូង (ទក្ខិណាបថ) ជាក្បែរភាគមាត់

សមុទ្រ មានទន្លេនិងព្រែកជ្រាយដ៏សម្បូរណាស់ តែគេមិនសូវមាន

ឈូងឆ្នេរសម្រាប់ជាទីអាស្រ័យនៅនៃនាវាទេ ត្រង់នេះ មាន

តែថ្ម ត្រង់កោះ មានទឹកកក់ពេក ត្រង់នោះទៀត កៀនកោះ

មានភក់ច្រើន ឯនោះគេទៅទៀតជាទីមិនមានគេអាស្រ័យសោះ ៗ

ដូច្នេះ កាព្យនិពន្ធស៊ូវគេតមានខេត្តក្នុងកាតការនិយាក់សម្បូរ
នេះទេ មានតែកាព្យធម៌ជាតិនិយមជនជាតិទេរបស្ចិម ទឹង
កាព្យតាមបែប ទៅតាមបុរាណបំផុតទៅទៀតនិងសុខក្សត្រ ។ ហើយ
លើកលែង កុំតែប្រហែលក្នុងកាតតាំងពីសម័យនេះបញ្ញ ហើយហើង
តំណាងការលើកខ្លួនប្រកបក្នុងប្រយោគ (Antithèse) គឺប្រើសូត្រផ្ទុយគ្នា
នៃប្រទេសក្រិកនិងកណ្តាលនេះវិញ ឲ្យតែងបាទមានការផ្ទុយគ្នា
ដូចមេឃនិងដី ឃើញថា ហេតុមិនដែលមានទិដ្ឋភាពជាប្រាកដ
គេកំណាព្យនៅ ។ ម្យ៉ាងទៀត ប្រទេសក្រិក មានទឹកដីហេឡាដ
(Hellade) តូច ឯទេសសម្បូរណ៍ដោយភ្នំ ។ មានកំពង់ មាន
កោះ គឺនៅទីវាលខាងជើងហើយផ្លែផលកើតមនុស្សមួយបែប
កើតកាព្យធម៌មួយបែបគឺបែបក្រិក ឯទីវាលផលកើតមនុស្ស
មួយបែបនិងកាព្យធម៌មួយបែបទៀតនោះ គឺប្រទេសកណ្តាល
បុរាណនេះឯង ។

ការមើលទឹកដីកណ្តាល មិនមែនមានឲ្យយើងយល់ទៅបុរាណ

សុភាសិតគ្រិកដែលថា "មិនមានអ្វីដែលលើសពេកទៀត" នោះ ទុកជាការត្រូវពិតមែនខាង ៗ ធម្មជាតិវិកលនៃឥណ្ឌា កាចរឹងរបឹង ណាស់ មិនអាចនឹងប្រព្រឹត្តទៅតាមចិត្តមនុស្សលោកឡើយ ភ្លៀងស្រួចតែម្ដងៗ មានបរិមាណច្រើនអស់ ៗ មើលចុះ ទន្លេគង្គាពលឹក ដី អាកាសធាតុក្ដៅ មេឃស្រឡះ ព្រៃព្រឹក្សក្រៀមក្រោះស្ងួត ការទាក់ទងគ្នាគ្រប់ត្រៃ ៗ មើលចុះ ! មហាបពិត្តទាំងស់ ត្រដួតត្រដ៏ម ព្រោះផលដំណាំរបស់ហេតុក្នុងប្រទេស ជាតិ មនុស្សច្រើនបែប ច្រើនយ៉ាង ដែលមានវណ្ណៈទៀត ៗ ការ ទាក់ទងវិញ្ញូលគ្រប់គ្នាមើលទៅធម្មជាតិវិកលឥណ្ឌានេះមិន ព្រមឲ្យគេធ្វើបានងាយស្រួលទេ វិស្វករនៃការទាំងទុំណាបថ ស្រូវតែឧបកម្ម ជួរជាតិធ្លាប់ទាមទារពញកាន់ដៃ ឯវិស្វករ ជួយគ្នាស្រាវជ្រាវ ស្រូវតែវិកលក្ខណៈ បុគ្គលឲ្យប្រើប្រាស់ស្រ-ដោយពង្រីក ៗ ទីហ៊ាននៅក្នុងបំពង់ដងធំក្រុមស្ដែង មិន មានចុកមិនចាញ់ទីក្រុង តាំងពីភូមិភាគឡាហ៊រ (Lahore)

រហូតទៅដល់ក្រុងភគល់ពុរ (Bhagalpur) មានចំងាយប្រមាណ

ជា ១.៥០០ គ.ម. ។ នៅក្នុងភូមិភាគទាំងនេះ ប្រជាជន

រស់នៅច្រើនណាស់ ហើយអាស្រ័យនៅក្នុងរីកចំរើន តែបើ

បើលើកឡើងដំណើរទៅទៀតឃើញថា ប្រជាជនទាំងប៉ុន្មាននេះ នៅ

ក្រោមសុខភាព ខ្ពស់ជាងខេត្តខាងលើ ។ ក្រុងធំៗ

របស់ឥណ្ឌា ក្រៅតែសង់តាមបច្ចុប្បន្ន ជាក្រុងបុរាណ គប្រ

ទិដ មានក្រុងឋិតថេរដូចជាក្រុងពារាណសីដែលឋិតថេរចាប់ពីកាល

រហូតតាំងពីព្រេងនាយមកនោះហើយ មានច្រើនតែក្រុងបែប

ក្រុងដែលគេបោះបង់ចោលកប់នៅកណ្តាលព្រុំព្រៃ ឬការ

កាលខ្ទេចខ្ទី ដើម្បីនឹងហៅថា "ក្រុងទៀន" ក៏សឹងបាន ដូចក្រុង

បាតលិបុត្រ ក្រុងកាលកត្តាជាដើម គេហដ្ឋានអាគារ នៅក្នុងក្រុង

ទាំងនេះតាំងពីដើមរបស់ បាក់បែកដូចជាក្រុងបុរាណដែរ ។ មនុស្ស

ជាតិដែលនៅក្នុងប្រទេសឥណ្ឌាទាំងមូល ក៏ហាក់ដូចជាវិក្រិត

វិលវល់នៅតែក្នុងមហាវិនាសដ៏ធំ ចង់លេចឡើងនេះដែរ ។

សភាពទឹកដី– ប្រទេសឥណ្ឌា គួរទុកជាប្រទេស ឧបទ្វីប ។ ភាគទក្សិណនៃឥណ្ឌាហៅថា ដេកង់ (ទ.ទក្កណ ត.តក្កណ, ប.ទក្ខិណ, សំ.ទក្សិណ "ត្បូង, ទិសត្បូង") ជាទីរាបខ្ពង់រាប កាលពីបុរាណនោះ ជារូបគន្ធូណា (Gandwana) ជាប់ភ្ជាប់ទៅដល់កោះ អូស្ត្រាលី (Australie) កោះម៉ាដាកាស្ការ (Madagascar) និងទ្វីបអាហ្វ្រិក (Afrique) ។

ដីខ្ពង់រាបពីបុរាណនេះ ជាភាគដ៏រឹងក្រៃពេក ដោយមិនសូវប្រែប្រួលណាស់ មានសមុទ្រនៅជុំវិញនៅខាងទិសត្បូង, លុះចំណេរប៉ុន្មានកាលមក ក៏កាលនោះ ភាគនៃខាងខាងកើតរណ្ដាតខ្ពស់ៗ ឡើងបើបកើតភ្នំនៅជាជួរ ហិមាល័យ ឯសមុទ្រ ក៏កាលនោះ ល្បាប់ដែលបាចកខាងកើតទៅចាក់ យូរទៅនាំឲ្យប្រាកដជាគោក កើតជាទៅជាដីទំនាបវាលឥណ្ឌូ-គង្គាមានក្រមាស់ ៥.០០០ ម៉ែត្រ នៅក្រុងកាលកាត់ ល្បប់ដី

ទៅភាគលិចភូណៅ (Lékhnau) មានកម្រាស់ ៤០០០ ម៉ែត្រ ជាដីមានជីជាតិល្អណាស់ ។ ឯសមុទ្រគឺចយទៀតទៅខាងទិស បស្ចិម ហើយទុកទីបាននេះដើមកំណើតជាគ្រួសារយ៉ាងធំដែល ឈ្មោះថា ទន្លេ "ស្នា-ព្រហ្ម" (តាមលោក Poscoe) ដែលចេញពីភូមិភាគអាសាម (Asam) ទៅដល់ភូមិភាគបញ្ចប គឺពីឧត្តរទៅបស្ចិម កប់យកត្រួសនិយមហានទីគង្គានាំមូលនិ ភាគមហានទីសិន្ធុនិងគង្គាបរិធី ។

ចុះហេតុដូចម្តេចក៏បានជាមហានទីគង្គា ប្តូរតាមផ្លូវទឹក បច្ចុប្បន្ននេះវិញ ? បាលោយមានការស្រុតដែនដីចាស់ ដូច ជាការស្រុតដីនៅចន្លោះភ្នំគារោ (Garo) និងភ្នំរាជមហាលជា ដើមដែរ ហើយជាចំបងមហានទីនេះ គឺស្ទុង គង្គា ជា ២ កំណាត់ មួយផ្នែកបានជាមហានទីគង្គា មួយចំណែកទៀត បានជាមហានទីព្រហ្មបុត្រ ។ ឯស្ទឹងសរស្វតីសព្វថ្ងៃនេះ ជាស្ទឹងតូច តាមគម្ពីរវេទ ជាស្ទឹងមួយធំណាស់ដែរ ព្រោះគេ

បានឃើញជ្រលងនៅតាមវាលខ្សាច់ ត្រង់ភូមិភាគថារ (Thar) ដែលជាស្ពានប្រឡាយធ្នារមេទឹកមួយធំ ហូរចេញមកពីតំបន់ ស៊ីមឡា (Simla) តម្រង់ទៅភាគក្រោមនៃមហានទីសិន្ធុ ។

ផ្ទៃដីភ្នំដែលហៅថា “ទ្វីប កោះ” នេះ ដូចជាចម្លើយថា កាលដើមជាដីកោះ គឺដីដែលមានទឹកព័ទ្ធជុំវិញ ដូចជាប្រជុំកោះនេះសមដែរ ។ បើយើងមើលដោយពិនិត្យពិច័យដើម្បីនឹងឃើញថា ភាគដីភ្នំខាងភូមិភាគទក្សិណជាខ្ពង់រាប នៃភាគដីដែលនៅតាមជ្រលងឥណ្ឌូ-គង្គា គឺតាមជ្រលងមហានទីសិន្ធុខាងបស្ចិម ត្រូវទៅដល់ទិសឧត្តរ និងជ្រលងមហានទីគង្គា ដែលទៅខាងទិសបូព៌ា ជាដីរាបទាំងអស់ កាលពីបូរាណត្រូវទាយ ទំនងជាឈូងសមុទ្រដែលព័ទ្ធជុំវិញខ្ពង់រាប គឺភូមិភាគទក្សិណនេះឯង ។ កាលពីអតីតកាល គឺកាលដែលភូមិភាគទក្សិណនៅជាកោះនៅឡើយ ជនខ្លះផងនៅកោះ កាលនោះ មើលពីកោះខ្ទង់កាត់លំហសមុទ្រដែល

តិចខ្ញុំវិញនៅខាងវិសុទ្ធ ហើយក្តិកុលបុត្តកំឡុងមហាបពិត្រ
មហាបពិត្រ ដែលស្រាប់តែយកព្រះខ្លួនកសាងកសិក្សសក្តិផុត
ហាងផ្ដែកកាកយស់ព្រះការវិស្ស ជាហេតុធ្វើឲ្យព្រះរាជ្យបក្រុម
កិច្ចការពារបាត់ខាងហើយថា "ហេតុសូត្រ" ឯរូបភាពវិញ្ញាណ
ជាជីការខ្ទង់ ក្រៅគេនគរខ្លួនថា "ហ៊ុំមនុស្សលោក" ។
ហេតុនេះវត្ថុ បានជាលោកហៅថែមជី ឥណ្ឌាហ៊ូនេះ ដែល
មានសភាពរូបគោលមកឯងនៃឈើថា "ស្រូវ" ? ។

រឿងព្រេងខ្មែរ មានដំណាលប្រាប់មកថា ថែងឥណ្ឌា
នេះជាមេទ័ព កុំសុំខេត្ត ជាហេតុកែការស (ហៅថាលើយ ?)
បិតនៅបំពាក់កណ្ដាលចក្រវ៉ូ មានតំរុយក្លឹកណ្ដ ៣ សត្ត-
សីខត្ត ៧ នោះតាំងវិញ ទ្រង់ពីជ្រូវទ័ពទាំងបាននេះ ព្រោះ
ចិតសម្ពុទ្ធវាន់នេះ ជាថ្មីកសិក្ខស ពួកយកចូលពណ៌ទៅ
សូត្រដែលលិចបាត់ទៅអស់ សូម្បីតែភេបស្អាប់បក្សីព្រួយយក
លិចបាត់ទៅដែរ មានតែព្រះមហាបុណ្យគេ ទើបនៅបាន

អាចឆ្លងទៅបាន បើចង់ទៅទៀត តែងតែជិះសត្វជ្រូ ដូចគ្រុឌជាដើម ហើយហោះនាំឆ្លងយកទៅ ៗ រឿងព្រេងខ្មែរនេះ យើងមិនអួតការជាជាសេចក្ដីពិតទេ តែយើងទុកជាគន្លឹះមួយដែរ ក្រាបទឹងព្រាលមើលសេចក្ដីពិតជាដូចម្ដេច ៗ

អាកាសធាតុ– ដែនដីក្ដៅផល់ប៉ោះ រ៉ូ ៗ ក៏ប្លែកគ្នាដែរ អាកាសធាតុមានប្រែប្រួល លក្ខណៈការរស់នៅប្លែកគ្នា ប្រទេសខ្លះផ្សេងៗ គ្នា ភាសាផ្សេងៗគ្នាដល់ ៩៤៩ ភាសា មហាភាសាធំនៃរស់នេះ ធំភាសាមាន ១៤ គឺ ហិណ្ឌី, តេគូលី, មកបី, គុជរាទី, បញ្ចាប់; ភាស្ទី, សិន្ធី, ឧរិយា, តមិល, មលយាឡាំ, តេលុគុ, កន្នរ; គោណា, គោលរ ៗ បើដើរកាត់ប្រទេសក្ដៅធំបំផុតពីឧណ្ហភូមិ (Fournaise) នៃខត្ត (Tropique) នៅតែក្នុងប្រទេសតែមួយនេះ យើងនឹងបានប្រទះអាកាសធាតុគ្រប់បែប គឺតាំងតែពីអាកាសធាតុបែបដូចទឹកកាំងបៃ (Bain de vapeur) នៃភូមិខ្សែវា (Equateur)

រហូតដល់អាកាសធាតុត្រជាក់បែបទឹកកក "ហិម ក៏ត្រជាក់" (F.frimas) ដែលជាទីឋានទឹកកកខ្ទប់នៃទ្វីបអាស៊ីកណ្ដាល ។ ប៉ុន្តែប្រទេសនេះ មិនសូវមានខ្យល់ប្រកខោប(១) (Mousson) ដែលទុកជាខ្សែជីវិត គឺជាប្រភពនាំឲ្យមានការរស់នៅទេ ។ រយៈកណ្ដាល (Latitude( នៃប្រទេសនេះជាទីឋានសោះក្រោះ (Arido) ទីឋានខ្សាច់អន្ទ្វីប ជាទីឋានធំសម្បើម ហើយមិន នៅជិតមហាបព៌តហេមពាន្ត ទីឋាននេះគេហៅថាស្រយាលពី សមុទ្រពេកណាស់ មិនសមបើអាស្រ័យនៅបានទេ ប៉ុន្តែមាន ខ្យល់និងភ្លៀងច្រើនប្រភេទបានជួយឲ្យអាកាសក្ដៅនេះត្រឡប់ ទៅជាអាកាសត្រជាក់ស្រួលបន្តិចវិញ ។ ប្រទេសណាដែល យើងថា មិនសូវមានខ្យល់ប្រកមោមនេះ បានត្រូវឲ្យយើងដឹង កល់គន្ធាំ គឺពីវៃវិចិត្តការទៅវល់ទឹកនៃខ្ទសកា ។ គួមិភាគក្នុង ប្រទេសភាគច្រើន ដោយពិសេស ភាគខាងទិសឧត្ត

---

១ ត្រូវប្រែថា "ខ្យល់វស្សានរដូវ" ព្រោះពាក្យ Mousson មកពីភាសា អារ៉ាប់ ប្រែថា "ភ្លៀង" ។

ក្នុងសិសិររដូវ (វិច្ឆិកា-មីនា) សុទ្ធតែជារដូវរាំង ហើយដាច់ស្រយាលពីសីតុណ្ហភាពពេកណាស់ ។ បន្ទាប់ពីការក្ដៀងខែ វិច្ឆិកាទៅ ព្រៃព្រឹក្សលតាជាតិស្វិតស្រពោនក្លាយ តិណ-ជាតិក្រៀមក្រញាំអស់ ខ្យល់ស្ងួតខែស ស្ទើរតែពុំសល់ពុំន ក្រុបកកំផុយអបរិលគស់ផែរ ពេលយប់ រាត្រីស្ងាត់ត្រជាក់ស្រួល អាកាសស្រួលណាស់ ដោយតាំងស៊ីព្រះអាទិត្យខ្លាំងហួស ពេលថ្ងៃ ព្រះអាទិត្យចាលរស្មីបកខ្លាំងពេក មិនមានអ្វីបាំងសោះតែមិនរនៈដែនដីទេ មនុស្សក៏មិនរលាយដូចក្រមួនដែរ ហើយមានខ្យល់បក់មកហើយនាំតែយព្រៃសង្កែ ជាខ្យល់ស្ងួតដែលបក់មកពីខ្ពង់រាបខែកាសុីកាតកណ្ដាល ។ សីតុណ្ហភាពមធ្យមក្នុងខែមករា ចំនួនទាក្យអង្សារ នៅក្រុងមូលតាន (Multàn) ១៥ អង្សា នៅកាលកត្តា (២២-៣២), ២០អង្សានៅពង្គលូរ (Banga-lùr) (១៤-១៧) ។ ពេលសន្ធ្យាក្រតី សីតុណ្ហភាពធ្លាក់ចុះមកព្រឹម ស្ទើរតែគ្រប់តំបន់ដែលនៅក្រោមខ្សែត្រូពិក (Tropique)

សូម្បីតែនៅខាងការនទក្សិណផុត ក៏មានសភាពប្រហែលគ្នាដែរ គេត្រូវដុតចង្ក្រានភ្លើងអាំងទើបនៅបាន ។ នៅទីឯឡា-ហ័រ (Lahore) ទឹកក៏កកហើយ, នៅបណ្ដាមន្ទីរកផបុត្រស្ដាន សីតុណ្ហភាព ចុះមកដល់ ៥ អង្សា ។ រដូវនេះ ហៅថារដូវហេមន្ត (សំ.ហិម. Lat.Hiems. F.frimas, A.frost) តាំងពីពាក់កណ្ដាលខែវិច្ឆិកា ទៅដល់ពាក់កណ្ដាលខែមករា ។ រដូវ "សិសិរ" (សំ.ឝិឝិរ "ត្រជាក់", F. froidure, A.cold) តាំងពីពាក់កណ្ដាលខែមករា ទៅដល់ពាក់កណ្ដាលខែមីនា ។

អ្នកសិកភិត រីករាយសប្បាយចិត្តណាស់ កាលណាបើឃើញរដូវត្រជាក់ល្អមកដល់ ព្រោះហើយៈបះតែរម៉ឹង ចាំមើលស្រូវនឹងបានទឹកភ្លៀង ធ្លាក់មួយមេពីរមេនៅក្នុងខែកុម្ភៈ ធម្មជាតិហាក់ដូចជារីកស្រស់ត្រាប់បើ ព្រោះដីស្ងួតបែកក្រហែងនោះបានទន់សើមបន្តិច ។ ស្រែខរដូវមិនបានទុកទឹកទុកជាតិឲ្យនៅតែខៀវស្រងាត់ទេ មើលទៅមេឃឃើញផ្ទៃខៀវស្រឡះ

ក្ដៅជានិច្ច ឯសន្ធឹកៈឈើដែលស្ងួតក្រៀមក្រញ៉ង់ ដោយកំដៅព្រះអាទិត្យនេះ រុះជ្រុះចុះអស់ នៅតែដើមជ្រឹង សុទ្ធតែមានៈស្គមឃើញតែឆ្អឹងរំលេចគើង ខ្នងក្បាលចុះស្រងក្ដៅដីដែលបែកក្រហែងក្រៀមក្រោះល្ងាល្ហល់ផាច់គខ្ទុយក្អែក ដោយទឹកប្ដូរស្រងូតស្រងាត់ម្ដងគួរឲ្យខឹកអាណិតក្រៃលែង មានតែបុប្ផាតែមួយមុខប៉ុណ្ណោះទេ ដែលហ៊ានចេញមុខយកកេរ្តិ៍ស្គាយនៅជើងគុម្ពឈើ ក្រោមដើមក្រៀមក្រពើង ហើយបញ្ចេញពណ៌ក្រហមឆ្អៅមក ស្រស់ញញឹម ទោលក្នុងក្រអូបក្ដួយល្អបក្រឡុប់គ្នាដោយ មុនគួរឲ្យពេញចិត្តរមិលមើល ដូចជាចង់បង្អួតអ្នកទេសចរថាគ្មានបើ បើហៅទេសភាពបែបនេះតែមួយមាត់ឲ្យថា គួរនិងនិយាយថា «សម្រស់ទេសភាពឥតគតិកែ» (នេះគឺផ្កា Butea frondosa, Hi, dhàk ឬ palàç «Flame of forest») ។

គិបក, សព្វព្រៃភាពនេះតែល្ងឹងក្ដល់ថ្ងៃ ខ្យល់ក្ដៅដូច

នេះ មកប៉ះលើខ្ពង់ស្ទើរខ្វាច ខាងត្រីកាល ក៏ស្ទើរតែត្រាំ
មិនបាន សូម្បីតែនៅលើកងហាល ក៏មិនមានខ្យល់នេះហើយ
កំរេះបរលោះដែរ ។ នៅខែមេសា មានការកំរើបរដ្ឋមួយ
បែបត្រូបសង្កត់ខ្ពង់ទៅតាំងបទុស្សតាំងសុក្ក តាំងរសគ្នាទាំងអស់
ធ្លាក់ចំនួនវាចាជាខ្ចី គិតឲ្យកែប្រែមួយគ្រប់ពុញបប់នេះកន្លងផុត
ស្រះខ្វះទៅតែប៉ុណ្ណោះ ។ នៅកណ្ដាលកាល ឧណ្ហភាព
ឡើងដល់ ៤៥ ទៅ ៤៧ អង្សា ក្ដៅលើសពីកំដៅក្នុងខ្លួន
មនុស្សតិ ៩ ទៅដល់ ៨ អង្សា ។ ឧណ្ហភាពក្រោយឡើង
ហួសនេះទៅដល់ ៥ អង្សាក្នុងម្លប់ មិនមែនទៅតែតាមជនបទហា-
ឧទ្ធិសជនបទនៅក្រុងជាកោបាបាទ (Jacobabad) ក្រុងមូលតាន
(Multàn) ឬ ម៉ុងគោមេរី (Mongomery) ប៉ុណ្ណោះទេ សូម្បី
នៅក្រុងជោតពួរ (Jotpur) នៅកណ្ដាលស្ថាន ឬក្រុងអាក្រះ
ដែលនៅតាមជនបទឆ្នេរជម្នា (យមុនា) ក៏ដោយ ស្លុងតែក្ដៅ
ដូចគ្នាដែរ មិនមែនអស់ហើយទេ នៅមានខ្យល់ព្យុះខ្សាច់កាច

ទៀត  ព្រោះបើអាតក្ខជងដីគពាសពេញទាំងថ្ងៃនគាល័យ ពេញមកតាំងពីព្រលឹម មើលទៅមុខគួរឲ្យគក់ស្លុតក្រៃពេក ៗ ដោយអាកាសធាតុក្ដៅពេកខ្លាំងដូច្នេះ សន្ទឹកត្រីក្ដុលតាមតំបន់ផ្សេង អស់ពពីងពង មនុស្សសត្វ ហាក់ដូចជាអស់ខ្យល់ដកដង្ហើម ៗ ប្រសិនបើជាខ្វះខ្យល់ត្រជាក់ គឺស្បែកស្ងួតមិនបកទេ មើលទៅ ប្រហែលជាអស់ពីពន្លកទាំងអស់គ្នាមិនខាន ព្រោះបញ្ចក់ថា មិនមានខ្យល់ត្រជាក់ (ស្បែកស្ងួត) មិនមានជីវិតទេ ; ចាប់តែរុក្ខជាតិ ឬ ឫក្សា ទាំងមនុស្សទាំងសត្វតិរច្ឆានផងក៏សន្សើយ ហើយ នេះជាអាកាសធាតុបែបអស្ចារ្យនៃប្រទេសកម្ពុជា ។

វស្សានរដូវ — ក្នុងរដូវនេះ ប្រទេសកម្ពុជាមានអាកាស ពេលខ្លះក្ដៅផ្សាល់ខ្លាំង ៗ ប្រទេសកម្ពុជា ដោយពិសេស នៅភាគខាងកណ្ដាល សួសើមជាទីហានដែលមានសម្ពាធភាព តែងតែទាញយកខ្យល់ពីសមុទ្រ, ដែលនៅនាសកោះទៅហើយ ទើបបានពពកខ្យល់ម៉ាសូរ ដ៏ខ្យល់ត្រូវបក់មកពីទិសនិរតីវិញ

ឯភាគ "រះមេឃទូត" ថិតនៅក្បែរប្រជុំសន្ទឹប ។ នៅលើដី
ដែលគេកាត់ឆ្លងនោះនេះ ចំណុចទឹកភ្លៀងថិតនៅក្នុងសាក្រលែង
ដើម្បីប្រមូលភាពយកពាក្យនៅជុំវិញនោះឱ្យធ្លាក់ជាភ្លៀងធាប់ៗ
រដូវគេហៅរដូវខ្យល់ចូកទាម (វស្សរដូវ) រីឯខ្យល់ចូកទាម
កាលដែលមកនោះ មាននាំការដួលជាគ្រោះដ៏ខ្លាំងណាស់
គឺពពកផ្គរខ្លាំង ដែលហោះហើរចេញពីមហាសមុទ្រឥណ្ឌា
មកនោះ មកជួបជាកន្លែង(១)ដែលលុកចូលទៅក្នុងសមុទ្របួ
ណយ ហើយធ្លាក់ចុះទៅលើដែនដីឥណ្ឌា ដូចគេចាក់ទឹកទៅក្នុង
ពេណ្ឌ ។ គ្រប់ពិធីបុណ្យមិនកាសមាគ៌ប្រាប់ថាហេតុការណ៍
នៃធាតុអាកាសនេះជាទិច្ច ហើយតាមបីលគ្រៅបង្ខ្យល់ដែលមក
នៅពីមុនខ្លះទៀតផង ។ ខ្យល់ចូកទាមនេះចាប់ផ្ដើមពីថ្ងៃ
ទី ៣ មិថុនា នៅឆ្នេរសមុទ្រមឡាបារ (Malàbar) ថ្ងៃទី ៤
នៅកុំបៃយ៍, ថ្ងៃទី ១៥ នៅកដមុទ្រស្កាទទិន់នៅតង្គ័រ

---

១ - ក្នុងវេរ មានពិភពលោកជាប់ ភ្លៀងធ្លាក់ចុះមក ដូចញូហយាត្រាឯកនឹទិត

ថ្ងៃទី ២៥ ខែមករា, ថ្ងៃទី ៣០ ខែបញ្ចប ។ ពេលនោះ ហើយដែលដុំពពកត្រូវបែកជាផ្លេកបន្ទោរ និងខ្លះ ព្យុះភ្លៀង ក្តាំងខ្លាំងមហិមាដូចហែកមេឃ គ្រេងគ្រាំ ៗ ហើយគ្រហឹម គ្លីលព្យុះទៅវិញធ្លាយមុខគួរគត់ស្លុតក្រៃលែង ៗ នេះគឺជា បាតុភូតដ៏សម្បើមអស្ចារ្យ ជាការគម្រាមខ្លាំងឥតគណនានៃ ពលានុភាពមហាមេឃនៃពិភពលោក ដែលទំព័រអក្សរសាស្ត្រ អ្នកប្រាជ្ញបានពណ៌នាទុកថា លោកនេះទុកដូចជា "ទេវវិការ នៃផែនដី" សេចក្តីពណ៌នានេះ ត្រឹមត្រូវតាមពលានុភាពបាតុ-ភូត សមតាមសេចក្តីពិតបំផុតមុខគួរឲ្យកោតស្ញើចក្រៃលែង ៗ

ទឹកភ្លៀងធ្លាក់ចុះម៉ក់ដូចគេចាក់ទឹកដូច្នេះ សីតុណ្ហភាព ក៏ចុះថយ យ៉ាងលឿន មកនៅក្រោម ៧ ឬ ៨ អង្សា ។ ភ្លៀង ធ្លាក់មកនេះ ខ្លាំងមហិមា ជួនកាល ៦៤ ហ៊ុន ឬក៏ ៤៩ ម៉ោង ធ្លាក់មកច្រើនបំផុតរហូតបានជាឯកទគ្គៈ ក្នុងពិភពលោក ស្ថានីយពិនិត្យភ្លៀងនៅចេរ៉ាពុញ្ជី (Charàpunji = Ceràpunji)

នៅក្នុងរដ្ឋអាសាម (Asam) បានឃើញថា មានទឹកភ្លៀង ១ម៉ែ ០៣,៦ ក្នុង២៤ ម៉ោង ឬ ២២ម៉ែ ៩០៧ ក្នុង១ឆ្នាំ គិតជាមធ្យម ក្នុងមួយឆ្នាំ ១០ម៉ែ ០៧ ។ ភ្លៀងនោះ ហើយធ្លាក់មកអស់កាលយូរដូចនេះ បានគេកំណត់ហៅថា "សេក្ខន" "រដូវភ្លៀង" ឯអ្នកដើរសមុទ្រជាតិអារ៉ាប់ហៅថា មោសិម ( mousim ) ប្រែថា "រដូវភ្លៀង" ដែលបារាំងយកពាក្យនេះមកធ្វើជា (mousson) សំ.វស៌, ប. វស្ស, ប្រែថា "ភ្លៀង" ។ ទានដើមរដូវភ្លៀងនេះមកដល់ខែកក្កដា ជារដូវគ្រីស្ម(grisma) (ប. គិម្ហ) ប្រែថា រដូវក្ដៅ ។ រដូវភ្លៀងនេះហើយ ដែលធ្វើធម្មជាតិឲ្យភ្ញាក់ ឲ្យមានជីវិតរស់ឡើងវិញ សត្វទ្វេបាទចតុបាទ ផុះលោតសប្បាយ ហិចហើរត្រៀលត្រាត់ ឈើទាំងអស់ ឡើងខៀវស្រស់បំព្រង ដូចជាហេតុអស្ចារ្យមួយកើតឡើង ឯព្រៃព្រឹក្សលតាជាតិ ផុះលូតលាស់ សន្ធឹកស្មុកខៀវខ្ចីរលេក ឈើឡើងយ៉ាងអង់អាច បុចពន្លកចេញ

ផ្នែកមេឃមេឃទី ៧

ស្រុកខ្មែរនេះ បានជួយបន្ទំប្រទេស ឲ្យរួចផុតពី ខ្យល់ព្យុះ ត្រង់ភូមិភាគណាដែលទឹកដីនៅមិនទាន់ហួស ប្រមាណពេក ដែលនៅពេញទីល ទឹកដីនៅខ្លាំងទៀតលិចភូមិ-ភាគច្រើនកន្លែង តាមបាតបនផាប់ ហើយកេតត្រូវញាក់ទិស កេតកាតត្បាតញាំញីរួចទៅ ៗ នៅតាមពើងទេរ ខែមហាបក់ ពោយតាគ្គ ទឹកភ្លៀងដែលធ្លាក់មកខ្លាំង បានព្រោះជឲ្យកើត ទៅជាជ្រោះជ្រលងផងរូវ ទំលំពេលីបទឹកខ្លាំង នាំឲ្យកើតជា ស្ទឹងទិស់ព្រៃ ៗ ទឹកភ្លៀងនេះ ធ្លាក់មកមិនសូវសព្វទី កន្លែងទេ ខ្យល់ប្រែភេទម, កង់ស្រុកខ្មៅ, បក់មកត្រូវខាង វត្ថុណាបថភាគបស្ចិម ទិសភូមិភាគនៅផ្ទៃណ្ដាយតាមមហា បពិតពោយតាគ្គ ភូមិភាគបញ្ចាប់មិនសូវមានទេ ភូមិភាគខ្លះ នៃទក្ខិណាបថគឺមិនមានដែរ ដូចនៅតាមឆ្នេរសមុទ្រវិសបូព៌ ផាដើម ឯនៅខ្ពង់កោរកម៉ង់ដែល (ពោធិ៍ណ្ណាល) មានខ្យល់

ប្រកបដោយសើមណាស់ ទាល់តែមកដល់ខែតុលា វិច្ឆិកា ទើបមានខ្យល់ប្រកដោយ គឺខ្យល់បក់ច្រាសវិលមកវិញ ។ ហេតុដូច្នេះ ក្នុងភូមិភាគនេះ គេតែងដាំតែដំណាំស្រាល ៗ ដាំតែ ២ ឬ ៣ ខែបានផល ដូចពោត ២ ខែ ពូជស្រូវខ្វះ ៣ ខែជាដើម ហើយគេបើដាំទៀត តែដាំបានតែ ៣ ដងទេ ហើយប្រើផលប្រទាន (Irrigation) ដូចជាផង ។ ឯភ្លៀងដ៏ឃ្លាតពីគ្នាឆ្ងាយណាស់ យូរ ៗ មានម្ដង ឯថ្ងៃមេឃស្រឡះក្តៅ ៗ ក្នុងសរទរដូវ (សំ.គរង) តាំងពីពាក់កណ្ដាលខែសីហាទៅពាក់កណ្ដាលខែវិច្ឆិកា រដូវនេះ អាកាសស្មើគឺត្រជាក់ល្មម ស្លឹកឈើខៀវស្រងាត់ មើលទៅទេសភាពស្រស់បំព្រង គួរពេញចិត្តរមិលៈមល បានជាពួកអ្នកពណ៌នាសរសើរធម្មជាតិច្រើនប្រការណាស់ ក្នុងកាលនេះ គេតែងប្រញាប់ប្រញាល់ធ្វើកិច្ចការសព្វជំពូក ឲ្យហើយស្រឡះទៅហើយក្នុងរដូវនេះ ព្រះចន្ទបញ្ចេញពន្លឺត្រជាក់ស្រទៃតដ៏ភ្លឺ

គ្រប់គ្រងគ្រប់វិភពត្រី ជួយផ្ដល់មនោរម្យរីករាយសប្បាយ ដល់ប្រជាជន មិនគួរទឹងអានការពិនណាយឡើយ ។

អ្នកផណ្ឌិតខាងយល់ច្បាស់ខ្ទង់ដំណើរផ្កាយ គឺមួយឆ្នាំ យ៉ាងខ្វល់ខ្វាយណាស់ ។ គេយកពាក្យថា "វង់=គ្រៀង" មកធ្វើជាឈ្មោះ "ឆ្នាំ (១)" ព្រោះគេយល់ថា ការរស់នៅរបស់គេត្រឹមតែ ៤ ខែ គឺខែដែលមានវិតក្ដៀងធ្លាក់មកជាកជាំ ត្រជាក់ស្រួល ជួយទឹងរដូវក្ដៅ ៧ ខែ ដែលមានសុទ្ធតែ ក្ដៅបន្ទុះហែង ហើយគ្រប់គ្នាទំព្រាំរង់ចាំឲ្យចៀសទៅ តាមសភាពដំកើត ដែលមានគេថា ទុក្ខពុំគួរឲ្យជឿណាយ នេះក៏ល់វិភពត្រី គ្រប់តែរដូវ ថ្ងៃណាដូចថ្ងៃណា បើទុក ជាគ្រប់វណ្ណកាលវេលា ហួសប្រមាណកេត ជាន់គ្រប់វណ្ណ អាកាសក៏ដោយ គេក៏ស៊ូអត់ទ្រាំទៅបាន ។ គ្រប់ប្រទេស ដែលមានខ្យល់ត្រជាក់ខ្លាំង ប្រទេសក្ដៅក្លា ជាប្រទេសដែល

១– ឆ.ហិរញ្ញ អាចារ្យ ធម្ម: ថា ជនមិ ទេវជាខ្មែ.ថា "ឆ្នាំ" ។

មានរបៀបដូរគ្នាឲ្យសិក្សាច្រើនជាងគេបំផុត ។

**នានាភាពនៃភូមិភាគប្រទេសឥណ្ឌា** រីឯឧបទ្វីបឥណ្ឌាដ៏ធំ ដែលមានអាកាសធាតុខុសៗខុសភាពផ្សេងៗ ពីគ្នានេះ មានសហយោគ (combinaison) ច្រើនបែបណាស់ គឺមានធាតុភាពផ្សេងៗគ្នាខ្លះ មានភាពលាយគ្នាខ្លះ ហើយមិនសូវមានឯកភាពដូចប្រទេសឯទៀត ក្នុងប្រទេសតែមួយនេះ មានសុចិតការ (Assortiment) នៃភូមិភាគមិនដូចគ្នាសោះ មិនមែនដោយហេតុតែប្រទេសនេះ មានលក្ខណៈ៣ ផ្នែក គឺមហាបព៌តហិមាល័យនៅទិសឧត្តរ ទំនាបវាលហិណ្ឌូស្ថាន និងខ្ពង់រាបនៅទក្ខិណាបថទេ ប៉ុន្តែដោយហេតុតែក្នុងភូមិភាគនីមួយៗនោះ មានលក្ខណៈផ្សេងៗពីគ្នាទៅទៀត ។

**មហាបព៌តហិមាល័យ** – មហាបព៌តហិមាល័យជាជួរភ្នំដ៏ធំមហិមានៃមហាប្រថពី សណ្ឋិតបណ្ដោយគ្នាទ្រង់ក្រោយដូចធ្នូប្រវែង ២.០០០គ.ម. កម្រាស់ពី ២៥០គ.ម.ទៅ

៣០០គ.ម. ជាជួរបព៌តធំសម្បើមស្វាររៀងទៅក្នុងពិភពលោក ។ ដើមគេ, គឺជួរភ្នំដែលលយដូចជាដៃលៀនចេញមកប្រមាណជា ១.០០០ម. ឈ្មោះថាស៊ិវាលក្ខ (çivàlakh) ឬ ឧបគិរី មានរូបច្បាស់លាស់លេចចេញមកកាន់ទីវាល ។ តពីជួរភ្នំមកកាន់ក្រោម មានទីទំនាបធំទូលាយឈ្មោះថា ដូន (Dùn, សំ. ទ្រោណៈ ប្រែថា "ស្នូក") កន្ទុនឈ្មាន ជាទីឋានស្រួលមួយ ព្រោះមានមេទឹកហូរបោកបក ដូចជាភូមិភាគដេរ-ដូន (Derha Dùn) ដែលមានកំពស់ ៦៩០ម. ជាដើម ។ តទៅភាគខាងលើ មានភ្នំមួយទៀតគ្រង គឺភ្នំមសូរី (Masùri) កំពស់ ២.២០០ម. ជាជួរភ្នំទីមួយ ឬទីឯហៅថា អនុហិមាល័យក៏បាន តែអ្នកស្រុកគេតែងហៅថា "ភ្នំក្រៅ" ហើយមានទីទំនាបទៀត ទីឯថាជាវាលក៏បាន ដូចជាទីវាលនៅក្នុងប្រទេសនេបាល់ជាដើម ទើបដល់មហាបព៌តហិមាល័យ ។ ជួរបព៌តហិមាល័យនេះ លេចអណ្ដែតខ្ពស់ទៀនត្រដែត ជាប់

ប្រទាក់គ្នាជើត កំពូលស្រួចច្រើនព្រាង គេចូលទៅមិនបានទេ អ្នកស្រុកហៅថា "គុំភ្នំ" ។ មហាបព៌ត ដែលមានហិមៈជាប់និរន្តរមានកម្រាស់ទឹកកកធំបំផុតដូច្នេះ សមគួរនឹងបាននាមថា "ហិមាល័យ" ឬ "ហិមវន្តបព៌ត" ពិតប្រាកដ ។ មហាបព៌តដែលមានកំពូលខ្ពស់ទាំងអស់ថិតនៅត្រង់មជ្ឈបណ្ដាល ដែលមានកន្លែងដូចជា ដូចមហាបព៌តអេវើ-រេស្ទ (អេវើរេស្ត) ដែលជាប់នៅមហាបព៌តកញ្ចនជង្ឃធោលគិរី, ក៏នៅប៉ូម នៅជិតប្រភពមហានទីគង្គានី មហា-បព៌តនន្ទទេវី, នៅត្រង់កែងមហានទីសិន្ធុមានកំពូលមួយហៅនង្គាបព៌ត, នៅឆ្ងាយពីជួរបព៌តភាគខាងនេះ ជាខ្ពង់កប ប្រទេសទីបេត៍ដែលជាប្រភពមហានទីសិន្ធុ និងសត្លុជ (Satlaj) និងមហានទីព្រហ្មបុត្រ, ក៏នៅទៀត ជាដែមហាបព៌តហិមាល័យកំពស់ពី ៧.០០០ម. ទៅ ៨.០០០ម. ជាមហាបព៌តដែលលើខ្ពង់កបទីបេត៍ដែលមានកំពស់ត្រឹមតែ ៤.០០០ម. គឺបព៌ត

សង្ការ (Zankar) ឡាដាក់ (Ladakh) ការាកោរ៉ម និងជួរ បព៌ត ៤ ទៀតដែលមាននាមថា "កៃលាស" ។ មហាបព៌ត កៃលាសនេះ មានកំពស់ ៦.០៩៤ម ឋិតនៅក្នុងភូមិភាគឡាដាក់ ត្រង់ចំណុច ៨១° ទិសបូព៌ គឺជាតួមហាបព៌ត "កៃលាស" ដែលមាននាមល្បីល្បាញបំផុត នៅក្នុងអក្សរសាស្ត្រឥណ្ឌា មានស្រះមួយទៀត មាននាមល្បីល្បាញដូចគ្នាដែរ គឺស្រះ "មានសារោវរ" (អនោតត្ត ឬអនវតប្ត ?) ទឹកស្រះនេះ ហើយដែលពួកព្រាហ្មណ៍ហិណ្ឌូទុកជាទោលិកា (Berceau) នៃបុព្វបុរសហិណ្ឌូ ៗ តាមជំនឿ ពួកព្រាហ្មណ៍ហិណ្ឌូតែងតែ ទៅធ្វើធម៌យាត្រាទីនេះ ហើយលះបង់ជីវិតនៅមាត់ស្រះសក្តិ សិទ្ធិដ៏វិជ័យផ្ទុយដោយជំរុ មានទេសភាពខ្ពស់គួរឲ្យមានទុក្ខជូន ក្រៃលែងព្រមទាំងបំពេញកិច្ចចំពោះបុព្វបុរសគឺ "បិត្រ" រាល់ឆ្នាំៗ

**ទីបេនហេមវន្តប្រទេស** ជួរមហាបព៌តហិមាល័យជា មហាប្រាការដ៏សម្បើមអស្ចារ្យ ព្រួតបញ្ចូលគាត់មហាបព៌ត

នេះមានតិចណាស់ ហើយសុទ្ធតែខ្ពស់ដល់ទៅ ៣.៤០០ម,
ទៅ ៤.៧០០ម. ។ ឯដីខាងទិសទក្សិណនៃមហាបព៌ត មាន
ភាពទីទៃៗពីគ្នា មើលទៅឃើញច្បាស់ ត្រង់ភាគកណ្ដាល
និងខាងទិសបូព៌ ជួរភ្នំៗនេះ មានទំហំនកស្រ័យនៅតិច
ពេក ដូចប្រទេសភូថាន (Bhùthàn) និងសិក្កិម (Sikkim) ។
ឯភាគខាងបស្ចិម មានទីកស្រ័យនៅបានបន្តិច ដូចប្រទេស
នេប៉ាលនិងកស្មីរ ។ ភាគទិសទក្សិណនៃជួរភ្នំអនុបព៌ត មាន
វាលទឹកច្រើន ទាំងព្រឹក្សាជាតិដុះលូតលាស់ខ្ពស់ទៅ ។ នៅ
ជាយទីរាល បណ្ដាយតាមព្រំប្រទល់ប្រទេសនេប៉ាល មាន
ទីវាលមួយដែលហៅថា តារ៉ៃ Tàrài, (ផ្ទាស់: Tàr)
"សើម" ជាទីវាលភក់ក្រឡិបក្រខ្លាប់ ប៉ុន្តែបើបាច់ ឥតមាន
អនាម័យទេ ហើយជាតំបន់នៃព្រៃធំញឹកស្បាតបរិបូណ៌ដោយ
សត្វសាហាវដូចខ្លាជាដើម ទីនេះមានតែដំរីទេដែលជាពាហនៈ
អាចរុកក្រុលកាត់មហាសាគរតើមហារនៃនេះបាន ។ គឺទៅ

មានតែដីក្រួសរវៀនស្ងួត នៃបព៌តសំរាប់លក្ខ ជាដីដុះសុទ្ធតែ
ដើមសាលព្រឹក្ស នៅទិសខាងអនុបព៌តនេះ មានដី"ដុន" (Don)
មានសភាពដូចជាដីតាកស៊ីដេរ ដុះសុទ្ធតែរុក្ខលតាជាតិទៀត
ស្រស់បំព្រងដូចប្រស្បែដែរ ឈើធំៗ និងវល្លិជាតិ ៗ ទីខ្ពស់
តទៅទៀត ដុះសុទ្ធតែរុក្ខជាតិពពួកដូចដើមសែន (Chêne)
នូវយ៉េរ (Noyer) ប៊ូឡូ (Bouleaux) ដីមានដើមព្រោប
ដោយស្មៃក្រាស់ ឯដើមអាព្រីកូ (Apricotier) និងដើម
ប៉េស្ស៊ (Pêcher) គឺសម្បូណ៌ណាស់ដែរ ឯផ្លែវាបានជា
ចំណីអាហារនៃខ្មាឃុំ ៗ ទីដ៏ខ្ពស់ពី ២.០០០ម៉ តទៅទៀតមាន
ដើមម៉ាញ៉ូលីយ៉ា (Magnolia) ផ្កាពណ៌ស ឬក្រហម
ច្រាល, ដើមកូនីផែរ (Conifère) ដើមសែនខៀវ
(Chêne vert) ទីខ្ពស់ទៅទៀត មានដើម រ៉ូដូដែនដ្រុង
(Rhododendron) ដើមធំៗ ប៉ុនដើមនូវយ៉េរ តែរដូវក្ដៅ
គន់ទៅល្អមើលណាស់ ។

ភូមិភាគទិសបស្ចិម មានភាពផ្សេងពីគ្នាបន្តិច ព្រោះឧទ្ភិទភាពមានទំនងអាស្រ័យទៅបានស្រួល អាកាសធាតុល្មម មានវាលដុះស្មៅសម្រាប់សត្វពាហនៈល្អចំណាប់ ៗ ប្រទេសកស្មីរធំទូលាយហើយរាបស្មើល្អ សម្បូណ៌ស្មៅសម្រាប់សត្វពាហនៈ គឺជាប្រទេសស្រស់ មួយផ្សេងទៀត ការអាស្រ័យនៅធ្វើឲ្យរីករាយសប្បាយណាស់ អាកាសល្អដូចនៅទ្វីបអឺរ៉ុប មានស្ទឹង មានបឹង មានដើមដេវូដារ (Déodar) ដើមប៉ោម ៗ ក្នុងបច្ចុប្បន្នកាលនេះ មានដំណាំផលព្រឹក្សទំនើបថែមទៀត ៗ ភាគឧត្តរប្រទេសកស្មីរជិតនៅភ្នំការ៉ាកូរ៉ាម (Kàrakoram) មានភ្នំជាទីឋានអាស្រ័យនៅបានដែរ គឺទីឋានហ៊ុនសា (Hunzà) ដែលជាប្រទេសនៃពួកផនគុរុសស្តិ (Burusehasti) មានទំនប់ទឹកអាចធ្វើស្រែចំការបាន ហើយក្នុងសិសិររដូវជាទីរក្សាផ្កាព្រីកូ (Abricotier) ទៀត ៗ ភូមិភាគនេះ ជាច្រកចេញទៅកាន់អាស៊ីភាគលើបាន គឺច្រក

នេះហើយដែលប្រទេសកស្មីរធ្វើការទាក់ទងជាមួយបរទេស ។

ភាគបស្ចិមតទៅទៀត ជាទីឋានព្រំសីមាប្រទេសអ៊ីរ៉ង់ ហើយបព៌តដែលជាផ្លូវមហាប្រឹថពីប្រែសភាគទៅផ្សេងទៀតគឺ បព៌តការាកោរ៉ំ ជាប់តទៅបព៌តហិណ្ឌូកូស (Hindukuss) ដែលមានកំពស់ដល់ទៅ ៧.៣៥០ម. ជាទីឋានដ៏កលពេញ ទៅតាមមហាបព៌តហិមពាន្ត មានផ្លូវមួយដែលនាំទៅប្រទេសឥណ្ឌា តែផ្លូវនេះ មិនសូវជាស្រួលប៉ុន្មានទេ ដ្បិតមានច្រកពីរបើចូលទៅមកបាន ច្រកសំខាន់គឺច្រកខៃបារ (Khaiber) ដែលជាទ្វារបច្ចិមនៃប្រទេសឥណ្ឌា បន្ទាប់ពីច្រកនេះទៅ មានភ្នំវ៉ាស៊ីរិស្ថាន (Wazirithàn) និងភ្នំស៊ុលៃម៉ាន (Sulemàn = Sulaimàn) មានកំពស់ ៣.០០០ម ។ នៅខាងទក្សិណច្រក បោឡាន (Bolàn) មានទីឋានមួយធំ សណ្ឋានដូចផ្ទៃបើក គឺប្រទេសពលូចិស្ថាន (Balùcisthàn) ។

បព៌តទាំងនេះ ជាកំពែងមួយដ៏វែងតែស្គមក៏ត្រឹម ជា

ទាំងបាំងខ្យល់ត្រូវទាម តំបន់នេះក្តៅខេមកន្ទ្រ គ្រប់ខែ ឧសភា-មិថុនា កំដៅកំពស់ឡើងដល់ ៥៦ អង្សា នៅក្រុង ជាកុបាបាត (Jacobabad) តំបន់នេះហើយដែលនាំឲ្យ មានការកំណើតខ្យល់ទៅប្រទេសអ៊ីរ៉ង់ (Iran) ហើយឲ្យប្រែ ក្លាយទៅជាសភាពនៃប្រទេសប៉ាឡេស្ទីន (Palestine) វិញ ។ ទីហ្នឹងនេះ ក្រទឹកណាស់ ជាលំនៅនៃកុលសម្ព័ន្ធមួយក្រុម ដែលមានចិត្តរឹងរឹងរូស ហើយចូលចិត្តតែច្បាំង ។ ភាគ កណ្តាលខាងកាត់ឧត្តរ នៃភូមិភាគនេះ គឺជាប្រទេសកាប៊ុល (Kabul) កាលពីព្រេងនាយជាលំនៅនៃកុលសម្ព័ន្ធនេះ មុន កាលដែលពួកនេះចូលទៅដល់ប្រទេសឥណ្ឌា ។

ដល់សីមាមហានទីសិន្ធុ ភូមិភាគមហានទីសិន្ធុនេះ មិនមែនជាភូមិភាគមានអាកាសល្មម ឬត្រជាក់ល្មម ដែលជា ហេតុនាំឲ្យអ្នកកតត្បាត មានចិត្តចង់ចូលទៅប្រទេសឥណ្ឌាទេ ឬមិនជាមានហេតុដទៃទៀតក៏មិនមែនដែរ ។ អ្នកពិចារណា

រឿងនេះ បានទំត្រិះរិះរកគំនិតដើមនៃជនដែលចង់ចូលទៅ ថា តើហេតុដូចម្ដេចបានជាគេចង់ទៅកាន់ទីវាលបញ្ចាបនេះ គេថា អ្នកកគគ្យាកដែលធ្លាប់តែនៅក្នុងទីវាលស្មៅឥតដើមឈើ កាលបើឃើញទីវាលបញ្ចាប ក៏នឹកស្មានថាខ្លួនអាចនឹងញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅបានស្រួលក្នុងទីនេះ ព្រោះមានស្មៅ មានវាលស្មៅសម្រាប់សត្វពាហនៈ មានអាហារគោចរបរិបូណ៌ ។ គេនៅតែងខ្ទបចង់ដឹងទៀតថា ដូចម្ដេចបានជាអ្នកកគគ្យាក ដែលចេះតាក់តាំងគ្រោះ ហើយចេះជិះសេះភ្លូកនេះ មើលឃើញទីឋានដែលមានស្មៅជាដើមនេះ ថាជាទីឋានស្រួលសម្រាប់ខ្លួនទៅវិញ? អ្នកប្រាជ្ញគេយល់ថា ទីឋាននេះឥតជាការទេ មិនគួរនឹងចង់នៅឡើយ ។

មហាតទ្ទីសិត្ថ– កាលវារលូនបណ្ដោយតាមផ្លូវបាតហៀមតាន្តនោះ សិន្ធុហូរខ្លាំងណាស់ តែលុះចុះមកដល់ពាក់កណ្ដាល ត្រង់បត់ក្ងក់ដូចកែងដៃ ក៏បែកចេញជាផលមគ្គតូចៗ ច្រើន ក្នុងដើមរបស់ខ្លួនកាន់យកនាមថា "សិន្ធុ" ឯដៃ

ម្ដងទៀត គាត់យកងារថា បញ្ចនទ ឬបញ្ចាប (បញ្ច+អាប?) "សិន្ធុប្រាំ" តមក ប្រមូលគ្នាតែមួយ ហូរកាត់ទៅលើវាលខ្សាច់ មានឈ្មោះសិន្ធុមិនទៀងភក់ទេ តទៅនេះតែប្រមូលទៅទៀត ។ ក្នុងបុរាណសម័យ គឺសម័យដែលវេទធម៌ កំពុងចម្រើនខ្ពង់ខ្ពស់ មានអ្នកប្រាជ្ញខាងភាសាសាស្ត្រ បានបង់សិន្ធុទាំងនេះ ពុកគឺសិន្ធុឈេលម (Jhelam) ចនាប (Canàb) រ៉ាវី (Ràvi) សត្លុជ (Satlaj) និងព្យាស (Byàs) ដើម្បីបញ្ចូលទឹកទៅកាន់វាលលើបញ្ចាបភាគទិសបូព៌ ធ្វើទីនេះឲ្យទៅជាដីមានជីជាតិប្រសើរ ធ្វើផលស្រូវឲ្យបានបរិបូណ៌ តែក្នុងកាលតមក ផ្លូវទឹកនេះវិនាសបាត់បង់ទៅវិញ ។ ទីឋានដែលនៅឆ្ងាយពីផ្លូវទឹក ដោយពិសេសគឺភាគខាងត្បូងសិន្ធុសត្លុជ ជាវាលដែលគេហៅថា "ថារ" (Thar) មានសុទ្ធតែវាលខ្សាច់ធំធេងក្តៅអនេកអនន្តទ័ណ្ហា ដោយរាលស្មៅតែដើមឈើនៃផ្លាកជមុក្រស្នាន ។

**មហានទីគង្គា**– មហានទីគង្គា "មាតា គង្គា" គាត់

យកប្រភពទឹកនៅទីឋានដែលមានកំពស់ ៤.២០០ម. នាជើង បព៌តហេមពាន្ត ជាទីឋានធម៌យាត្រាដ៏ល្បីល្បាញ មាននាម ប្រាកដថា «គោមុខ=មាត់គោ» ។ តាមឈ្នារទឹកហូរចុះមក មានជលវេគច្រើនណាស់ មករួមគ្នា ទើបបានទៅជាបេទឹកធំ ហើយលូនតាមអនុបព៌តហេមពាន្ត រហែកទឹកដីបព៌តសិវលោក (çivalokh) ទីបំផុត មកដល់ទីឋានឫសីកេស (ក្បាលឫសី) ទើបចេញមកកាន់ទីវាលនៅក្រុង «ហរិទ្វារ» (ទ្វារព្រះវិស្ណុ) ។ រីឯហាងទីនេះ កាលចូលមកដល់ទីវាលហើយ ក៏ឋិតនៅលើកំពស់ផ្ទៃសមុទ្រ ៣១៦ម. ហើយរីកធំឡើងទៀត ហូរសន្សឹមស្រួលអស់រយៈចម្ងាយ ២.៩០០គ.ម. ទើបទៅចូលកាន់មហាសមុទ្រឥណ្ឌា ។ ពាក្យថា «មាតា គង្គា» ជាវិស្សុតនាម ជាមេទឹកធំមួយក្នុងពិភពលោក បណ្តោយ៣.០០០គ.ម. ទុំជាន័យមហានទីសិទ្ធបត្តិប ហៃមានទឹកច្រើនជាង ល្បឿនហូរថេរវត្ត ក្នុងវស្សរដូវ ទឹកឡើងខ្លាំង ដោយមានទឹកភក់ដែលរលាយ

នៅលើកំពូលភ្នំហេមពាន្តហូរចូលមកជៀជាមួយផង ៗ វិស័យមហានទីនេះ មានទំហំធំណាស់ ចំនួនជាងមួយលានគ.ម.២ ៗ សព្វថ្ងៃនេះ រដ្ឋាភិបាលឥណ្ឌា បានសាងទំនប់ទឹកស្ទាក់ច្រើនកន្លែងរួមទាំងអស់ប្រវែង ១៦.០០០គ.ម. មានព្រែកជីកវែងជាងគេប្រវែង៨០០.គ.ម.ជាហេតុនាំឲ្យខ្សែទឹកហូរខ្សោយទៅវិញ ៗ ដៃស្ដាំដ៏ធំនៃមហានទីនេះ គឺទន្លេជម្នា (Jamnà = Yemunà) ទន្លេជម្នានេះ មានដៃដទៃទៀតច្រើនហូរមកប្រសព្វដូចស្ទឹងចំបាល (Combal) និងស្ទឹងបេតវា (Betva) ជាដើម នាំឲ្យមានទឹកច្រើនទៀត ហើយហូរបណ្ដាយតាមគ្នាប្រមាណជា ១.៣០០.គ.ម. ទើបវិលទៅប្រសព្វមហានទីគង្គាវិញ នៅក្រុងប្រយាគ (Preyàg) ឬអល្លាហាបាទ (ក្រុងព្រះអលហ សព្វថ្ងៃនេះ ៗ ទីឋានដែលនៅចន្លោះមហានទីគង្គានិងទន្លេជម្នានេះ មាននាមប្រាកដថា «ទោ អាព» (ទោ+អាប ?) «ទឹក=ពីរ» ដែលគេទុកជាទីឋាន «មេសូប៉ូតាមី» (Mesopo-

tamie) មួយផ្សេងទៀត វីហារនេះ ដីមានជីជាតិល្អវិសេសណាស់ មានប្រជាជនកុះករច្រើនបំផុត គឺមាន ២០០នាក់ ក្នុងមួយគ.ម.² ។ វីហារនោះហើយដែលជាមជ្ឈមណ្ឌលនៃជនជាតិសាយ៉ែនពីបូរាណ ដែលមាននាមបញ្ញត្តិថា “សាយ៉ែកែ:” ។ លុះហូរទៅដល់ទីក្រុងពារាណសីហើយ មាត់គង្គានេះ មានទំហំប្រៀប ទទឹងពី ៨០០ម. ទៅ ២.០០០ម. តាមវដ្ដ ហើយទទួលពីទន្លេស្ទឹងសោន (Son) ពីខាងត្បូង ទទួលស្ទឹងឃាគ្រា (Ghoghra) និងស្ទឹងគណ្ឌក (Gandak) ហើយមានទំហំកាន់តែធំឡើងទៀត ។ កម្លាំងទឹកខ្លាំងណាស់ ក្នុងរដូវវស្សា កម្លាំងទឹកគឺ ១៤.០០០ម³ ទៅ ១៦.០០០ម³ គឺក្នុងពេលដែលបានទទួលព្រហ្មបុត្រដែលចេញមកពីប្រទេសទីបេត៍ ហើយហូរចេញឆ្លៀនតាមវដ្ដកសាប ហើយមករួមគ្នានឹងមហានទីគង្គានេះ កម្លាំងទឹកនេះខ្លាំងទ្វេ ក្នុងមួយវិនាទី ។ ដីសណ្ដនៃមហានទីទាំងពីរ

នេះមានទំហំធំណាស់ ប្រមាណជា ៨០.០៤០គ.ម.២ ធំជាងដីសណ្តទន្លេនីល ដល់ទៅ ៣ ឬ ៤ ដង ជាដីសណ្តធំជាងគេបំផុតក្នុងពិភពលោក ។

គង្គាប្រទេស គង្គាប្រទេសជាទីវាលធំធេងក្រៃលែង ការផ្លាស់ប្តូរកិច្ចការរុក្ខ ឬដំណាំផ្សេងៗ នៅទីនេះមិនឆ្ងាយពីគ្នា ដល់គ្នាទៅវិញទៅមកបានទេ កិច្ចការស្រុកភ្លូកតែងប្រព្រឹត្តទៅតាមតែទំហំរដូវភ្លៀង នៅតាមជម្រាលទឹកដី នៅតាមអាកាសធាតុ នៅតាមប្រពៃណីផងៗ ស័ក្តិសាកក៏ប្រព្រឹត្តទៅតាមទិសខែ ពីលើទៅក្រោម នេះតែងចង់ស្រេចទៅតាមធារទឹកហូរ-នទីនេះ តែទៅភាគក្រោម ទឹកភ្លៀងធ្លាក់ច្រើនជាងនៅវិញ ។ ជួរបន្ទះ គេអាចកត់សំគាល់បាននូវនាងតាកាតទឹកដីនៅចន្លោះទីហូរនៃភាគកណ្តាល (Doab-Oudh) ដែលនៅចន្លោះរដ្ឋឧត្ត-ប្រទេសនិងរដ្ឋពិហារមួយចំនួនតូចផង ។ រដ្ឋពេង្គាល់មានខ្យល់ប្រែប្រួលច្រើន តែដីសណ្តភាគក្រោមនេះជាដីលិចទឹក ។ ៤

រុក្ខជាតិ គេឃើញដើមឈើមានប្រភេទផ្សេងៗច្រើនដូចពួកសំ-
បួរ (Acacia Sénégal) ដំបងយក្ស (Cactus) អម្ពិល (ហៅ.អម្ពី)
ស្ដៅ (ample margousier, ហៅ.ឧម) ដុះតែខ្ចាត់ទៅ ៗ នៅភាគ
ក្រោមនេះ ហើយមានដើមស្វាយ, ដើមដូង, កុមុទជាតិ,
ដើមប្រែទៅវិញ ៗ វប្បកម្ម មានធញ្ញជាតិបូ (Blé) មីល្ញុក
(Millet, ហៅ. ក្វាំ, ពោធ្រោ) ដែលមាននៅខាងភាគលើ
ឯខាងភាគក្រោមមិនសូវមានទេ មានច្រើនតែអំពៅ, ស្រូវ,
គ្រប់ទៅវិញ ៗ សត្វស្រុក ទុដ្ឋមានតែភាគលើ ភាគក្រោម
មិនសូវមាន មានគ្រឹះវដ្ដពិហារ មនុស្សក៏មានចំនៀមទម្លាប់
ផ្សេងៗគ្នាពាល់ផាប់ ដោយជាតិ ដោយភាសា តាំងតស់ស្មុគ
តែចំរំវាទីពីគ្នា ធម្មជាតិទឹកដីដែលផ្សេងៗគ្នានាំឲ្យមនុស្សជាតិ
ផ្សេងៗគ្នាដែរ គឺប្រព្រឹត្តទៅតាមភូមិភាគឧត្ដរមហានទីគង្គា
ដែលមានជាតិជីតណ្ដួន, នៅភូមិភាគមហានទីនេះ, គ្រប់ភូមិ
ភាគមាត់ជលមត្ថខាងទិសទក្សិណ ដែលមានតែជាតិជីថ្មុះហើយ

មិមួណក៏ដោយថ្មចាស់ៗ ដែលជាប៉ាំងទុកណាបថ ៗ រួចរំលោ
បានសេចក្តីថា ទំនេះខ្យល់ប្រកែទាប (វស្សវដ្ត) ជាអ្នកឲ្យដើរ·
កាពកល់ឆ្នាំ, មាកាតគ្គាទឹកសក្តិសិទ្ធិ ជាអ្នកជួយសង្គ្រោះ
ជាអ្នកផ្គត់ផ្គង់ជីវភាព គឺដោយមាកាតគ្គានេះហើយដែលបាន
កើតភាយធំចំណ្ហានេះឡើង ដូចជាទន្លេនីលដែរ មិនគួរមាន
ក្តីមោះមន្ទិលសង្ស័យឡើយ ៗ ឯទីហានក់លកណ្ហាទៀតសោត
ក៏ដូចទីវាលប្រទេសអេស៊ីបដែរ បើនឹងបានផលកសេ្រចហើយ
តែពីទឹកភ្លៀងនេះឯង រឯពីតែសមុទ្រភាព ដែលមិនពេះទុនថយ
ទៅវិញនេះ ក៏កើតមកតែពីបហាប្រពានចាំង ៤ ដ៏ធំខាងលើ
នេះ គឺមាតាគង្គា ១ វស្សវដ្ត (ខ្យល់ប្រការនាម) ១ ៗ តែ
ប្រទេសកណ្ហានេះ មិនមែនមានភ្លៀងធ្លាក់គ្រប់ដូវទេ ក្នុងមួយ
ឆ្នាំៗ មិនសូវមានភ្លៀងធ្លាក់ស្ទើរតែអស់ ៧ ខែទៅហើយ ម្ល៉ោះ
ហើយទេសភាពមើលទៅមុខគួរឲ្យស្រងេះស្រងោច ឃើញតែ
ដូលីងីសព្រោន ព្រឹក្សាលតាជាតិមិនមានពណ៌ទៀវស្រងាត់

ស្រស់បំព្រង។ មានអ្នកខ្លះក៏ស្រងាកចិត្ត ដោយបានឃើញភូមិភាគទិសពាយព្យនៃក្រុងកាលកត្តានេះ មិនមានអធិកភាពនៃធម្មជាតិមិនត្រឹក្សាជាតិញឹកញាតស្បាតរបស់ប្រទេសដែលនៅក្រោមនិរក្ខន៍នេះឯង ។

ទក្ខិណាបថ – តាំងពីហុគ្លី (Hugli) ទៅដល់ជ្រោយកោ-មារិន (Kumàrin) ឆ្នេរសមុទ្រភូមិភាគនេះ មានឆ្នៃកូរ មានខ្សាច់ច្រើនស្ទួកហួតហែង ៗ ទិដ្ឋភាព ៣ យ៉ាងនេះ ត្រឹមត្រូវទៅតាមរចនាសម្ពន្ធនៅនៃភូមិភាគទក្ខិណាបថនេះហើយ ព្រោះជាខ្ពង់រាបប្រកបដោយជាតិថ្មផលិតដែលផ្ស៊ៀងពីវិន្ធ័រទៅភ្លៀសាន, មានកំពូលកំពស់ ផាកប្រែទៅទក្សិណប្រមាណជា ២.៧០០ម. គាទៅខាងបស្ចិម មានជួរបព៌តជាឃាត (Ghat = ជណ្ដើរ) ដែលលេចត្រដែតចេញពីសមុទ្រភ្លាម ៗ ជាយឃាតម្ខាងទៀត គំរលជ្រាលចាបលោម ប្រែទៅឈូងសមុទ្រពេង្គាល មានជួរភ្នំដាច់ៗ ដែលគេចុកជាឃាតដែលប្រែ

ទៅខាងទិសបូព៌ ។ ក្នុងតំបន់នេះហើយ មានខ្នងជារនាំងបាំង ខ្យល់ព្រុកនោះមិនឲ្យបក់ត្រង់ទៅទិសឦសាន ហើយថែរជា ឲ្យបក់ទៅទិសបស្ចិមវិញ បានជាភ្លៀងធំៗ មានច្រើនតែខាង ទិសបស្ចិម ឯទិសដទៃៗ មានបន្តិចបន្តួចស្ទួចស្តើងណាស់ ។

**ផ្ទៃរកោរាបដំរៀល**--ភាគទិសបូព៌ ជាពលភ្លៀងអនេក ព្រោះនៅក្រោមតំបន់ព្រះអាទិត្យ តែមានហេតុការណ៍ខ្លះនាំឲ្យ ស្រួលទៅវិញដែរ ។ ខ្យល់ព្រុកនោះមានសើមណាស់ មានតែកន្លងខែតុលា វិច្ឆិកា តែរដូវកាលក៏មានភ្លៀងធំម្តងៗ ដែរ តែពោះបេ្តចម្តា យកជាការពុំស្រួលបានទេ ព្រោះតំបន់ នេះតែងតែមិនសូវមានភ្លៀង បានជាចេះតែមានទុរ្ភិក្សរាល់តែ ឆ្នាំនៅខេត្តឧរិស្សា ។ ភូមិភាគទក្ខិណាបថនេះ សូម្បីមិនសូវមាន ភ្លៀងក៏ដោយ តែមានបើកច្រើនហូរកាត់ដូចស្ទឹងមហានទី, គោទាវរី, ក្រឹស្ណា, កាវេរីជាដើម ស្ទឹងទាំងនេះនាក់ទៅមកមិន បានទេ ដោយហេតុព្រោះស្ទឹងដើររដុបដោយថ្ម មានជួរ មាន

ទឹកធ្លាក់ តែមានទឹកច្រើនបរិបូណ៌ ដីសណ្ដមានដីជាតិធ្វើស្រែចំការបាន ប្រជាជនក៏មានច្រើន ដូច្នេះ ឆ្នេរទិសបូព៌ា ដែលបានឈ្មោះថា កោរោម៉ង់ដែល (Coromandel = coromandala = គោរមណ្ឌល) និងសិរការ (Circars = Sarkàr) នេះជាដីសណ្ដមានដីជាតិធ្វើស្រែចំការបាន ។ ពួកកវីជាតិតាមិលបុរាណ ជាអ្នកចេះសង្កេតប្រសើរ ចេះភូមិសាស្ត្រប្រាកដ បានពណ៌នាទេសភាពភូមិភាគនេះទុកល្អ គួរឲ្យចាប់ចិត្ត ខ្លា ថ្លែងថា «ស្ទឹងកាវេរីជាឧត្តមម័យដ៏ល្អឆើតឆាយ ចិញ្ចឹមទាំងលិចទិសបូព៌ឲ្យមានជីវិតរស់ ដោយសារទឹកនៃវស្សរដូវ ដែលខ្លួនបានទទួលពីឃាតបស្ចិម នាំយកមកដាក់នៅទីនេះ ធ្វើឲ្យដីមានជីជាតិល្អ ៗ ដោយហេតុនេះ តំបន់តញ្ជោរ (Tanjore = Tanjàvùr = តញ្ជាវូរ) និងតំបន់ការិកាល (Kàrikal = Kareikal) ល្បីល្បាញថាជាទីឋានមានដីជាតិបំផុតគ្រប់រដូវ គេទុកជាដើមប្រមាត់នៃជនជាតិតាមិល ៗ សព្វថ្ងៃនេះ មាន

ទំនប់ទឹកដ៏សម្បើមនៅមេត្តូរ (Mettur) ។ កាតមាត់សមុទ្រ មានកំពង់ធំច្រើន ឯកំពង់ពីបុរាណគឺ កំពង់ខេពេរិស (Khabèris = Kaverippattinam = កាវេរិប្បត្តិន័ម) នៃលោកប្តូ-ឡេមេ៉ (Ptomlémée) និងកំពង់ កៃល (Cail.) គា. កាយ៉ល (Kayàl), "ត្រពាំង ឬ ស្រែអំបិល" របស់លោកមារកូ ប៉ូឡូ (Marco Polo) នោះ កប់ទឹកលិចបាត់ទៅហើយ ។

ឆ្នេរម៉ាលបារ-ឆ្នេរម៉ាលបារ ជាបង្កាដីតូចចង្អៀត មានតែបឹងបួ បាំងដោយជួរភ្នំដែលគេហៅថាឃាត (Ghat = ជណ្តើរ) ដែរ ។ អាកាសធាតុក្តៅខ្សោះ ក្តៅអេនកអនន្ត ហើយទទឹកសើម ដោយភ្លៀងរលឹមជានិច្ច កើតឡើងពីវស្ស-រដូវដែលមកពីច្រកតីរ ។ មានព្រៃព្រឹក្សាសម្បើមអស្ចារ្យ ដើមដូង, ស្លា, ដើមកាលជាត់, កៅស៊ូ ចំរើនរុងរឿងណាស់ នៅតាមជំរាលភ្នំ ។ ផ្សេងពីដំណាំម្រេច តែ កាហ្វេ មាន ព្រៃព្រឹក្សាទៀតស្រស់បំព្រង ដើមម៉ៃសាក់ ដើមពណ៌ស្វាយ

(Palissandre) ដើមបណ្ណគ្គជាតិ (Fougères arborescentes) និងគុម្ពឫស្សីធំៗទៀត ៗ នៅកំខ្ពស់ មានសត្វសាហាវដូចខ្លា ជាដើម ។ ឯក្នុងកប សត្វហ្មូកហែងណាស់ ដូចតំបន់ទាំងឡាយ មានម៉ៃសួរ(Maisùr)ជាដើម ។ ទីឋាននេះ មានជ័រច្រើនជាងគេ ។

ភាគឧត្តរទក្ខិណាបថ– គេទៅខាងភាគឧត្តរទៀត នៅតំបន់មង្គលួរ (Mangalùr) បត្តកាដីកែកែគួចទៅៗ ស្មើរតែមិនមាន, មានតែជ្រុះដើមរដុបតួចតឹក ហើយគេទៅ ដល់ភូមិប្រទេសមារាថី (Marathi) និងតំបន់កោនកាន (Konkàn) ។ នៅខាងឧត្តរភូមិប្រទេសមារាថី ទុទិន្នភាពប្រឹថពី មានច្រើនបែបណាស់ ដូយគ្នាស្រទ្បះពីភាពដែលមុខគួរឲ្យស្រនេះស្រ- នោចនៃភូមិភាគប្រទេសឥណ្ឌាខួទៅ ដោយមានជ្រលងស្ទឹងតាប្តី (Tàpti) និងស្ទឹងនម៌ទា (Narmadà) រហូតទៅដល់ខ្ទង់កបម៉ាល្យា (Màlyà) ទីនេះមានព្រៃក្តុំធំៗ មានស្សែរផ្លូវពោតបកបកក្តួនគិម្សផ្លូវ មានបឹងធំៗ ដែលហៅថា គន្ត

(Port. tanque, lat. stagnum = "ទឹកដក់") ច្រើន សម្រាប់ កក្ពុល់ទឹកទុក។ វិហារតាំងពីមាល្វា (Malva) ទៅវាល់ ឧជ្ជេន (Ujjain) វិហារទាំងអស់នេះ ជាវិហារដែលគេគរក្បោះស្រួ សំស្រឹតចំរើនបំផុតរហូតដល់ថ្នាក់ប្រណីតបរាជ្ញ ៗ នៅភាគ បស្ចិម ជាវិហារមានផ្ទុកបដិមាទៅក្នុងប្រទេសគុជរាត (Gujrat), ភាគខាងត្បូងមានផែនដីភ្នំអារាវល្លា (Aravala = Arevalli) មិនទី ណលមេះជនវៃកបឋកណបូជា ឯភាគបូព៌ានៃបាក់កាឡា មាន ឆ្ងាយពីក ស្ទុះតែជាវិហារមហាយានមិនដែរ មិនជាវិះគិតកេតម៉ន ប្រកបដោយរចនាបថនៃវដ្តបច្ចុប្បប្រទេស ។

ឯវិហារនៃខ្ពង់របទក្ខិណាបថ ត្រង់ផ្ទៃកណ្ដាលខ្ពង់រប ដូចជាភិបខៃហៈជកបាទមិនបៃស្ស ស្ទុះតែជាវិហារខ្ពស់ បាន កសាងពី ៧០០ប. ទៅ ៩០០ប. ហើយជាវិឡក់ខ្ញុយ ដ៏មាន ស្នូលតែក្រុសរះរៀន ក្រសត្រប់ក្នុង តាំងតែពីក្រុងមជ្ឈិមាទៅ ដល់ក្រុសជុំធំ ៗ គេយកក្រួសវាំងនេះទៅធ្វើជាគ្រឿងទព្វ-

សម្ភារៈសាងជាប្រាសាទកជផ្លួន ឬសំណង់អ្វីផ្សេង ៗ ៗ គ្រប់ទីណាដែលមានទឹក ទីនោះ គេអាចធ្វើដំណាំបន្តិចបន្តួចបាន ឃើញពិសេសចំពោះតែភាគនិរតីតំបន់ម៉ៃសូរ ព្រោះមើលទៅឃើញទេសភាពស្រស់ញញឹមបំព្រង គួរជាទីត្រេះថ្នាត្រាន់ប៉ើ ៗ នៅភូមិភាគម៉ៃសូរនេះ គេអាចសាងជាមហានគរដ៏ឆើតឆាយបាន ព្រោះនៅជិតទឹកខាង មានព្រៃព្រឹក្សា អាកាសធាតុត្រជាក់ល្មម ឯក្រួសគ្រប់គុន បានជាគ្រឿងទ្រព្យសម្ភារៈដ៏សំខាន់ ដូចក្រុងពេង្គលូរ (Bengalùr) នេះ មានសួនច្បារល្អវិសេសណាស់ ទីឋានទុកជាចំណតយានយន្តក៏ល្អបំណាប់ ៗ កាលពីសម័យព្រេងនាយក្រុងពេង្គលូរនេះ ជាក្រុងវិជយនគរមានប្រជាជន ៦០០.០០០ នាក់ សីតុណ្ហភាពមានកំរិតពី ១៨ អង្សាទៅ ១៩ អង្សា, មានកំពស់ខ្ពស់ពីផ្ទៃសមុទ្រប្រមាណជា ៩២០ម. ៗ ក្រុងពេង្គលូរដែលល្អឆើតឆាយនេះ គេទុកជាក្រុងគជពង្រាយនៃបូព៌ាប្រទេស (la perle de l'Orjent) ៗ

ធម្មជាតិទឹកដី នឹមហាក្លូតរូបនៃប្រទេសណា ដែលយើងបានសិក្សាមកនេះ ផងបរទេសគ្រប់គ្នា គោរពតែជាន់ដីនេះប៉ុកតិជើងក្លាមថា ទឹកដីនេះពិតជាបើងមែន បើងមិនទៅតាមមនុស្សដោយឆ្ងាយទេ តែជនណាក៏ជាអ្នកបើងមិនព្រមចាញ់ធម្មជាតិ ទំប្រឹងយកឈ្នះចាល់តែបាន ដោយប្រើវិយ-កាពជំមុះមុតតស៊ូកុប់ម៉ុនឆ្នាំ កែទម្រង់ធម្មជាតិដ៏រឹងរូសនេះ ឲ្យចាលចាញ់តេជះដៃមនុស្សជាតិ ហើយធ្វើឲ្យកើតជាប្រយោជន៍ ទីបំផុត បានសម្រេចផលសមតាមប្រាថ្នា នូវអស្ចារ្យនៅក្នុងទំព័រប្រវត្តិសាស្ត្រ គឺកាប់ឆ្ការរវៃព្រៃផ្សៃ ផ្លុំកាកាសធាតុ កនដីឲ្យក្លាយទៅជាស្រែចំការ សាងក្រុង សាងភូមិករគេហដ្ឋាន ប្រាសាទវិមាន ធ្វើទំនប់ទប់ទឹកបញ្ចូលស្រែចំការ ចនគម-នាគមន៍ទាក់ទងពេញប្រទេស ព្រមទាំងសាងមនុស្សឲ្យមានចំណេះវិជ្ជា ដែលជាប្រភពនាំឲ្យកើតទ្រឹស្តីគ្រប់ជំពូក ល្បីល្បាញក្នុងពិភពលោក ប្រាកដដូចក្នុងបច្ចុប្បន្នកាលនេះ ។

ជនឥណ្ឌាគស្ស៊ីយ៉ាំងក្លាហានគ្រប់វិធីតាមដែលគេបង្កើតបាន មិនចំពោះតែឈ្មួញផាត់ទឹកដ៏ប៉ុណ្ណឹងទេ គស្ស៊ីចំពោះសត្វសាហាវយង់ឃ្នងទៀត តែគេមិនប្រើវិធីហិង្សាទេ គេហាក់ដូចជាចេះធ្វើឲ្យសត្វសាហាវទាំងនេះ មានវិចារណញ្ញាណនៅវិញ គឺចេះទូន្មានដំរី ជាសត្វដែលមានរូបធំទ្យសាំង យកប្រើធ្វើជាសត្វស្រុក ធ្វើជាពាហនៈបាន ចេះទូន្មានពស់ដែលមានពិសឃោរឃៅឲ្យស្គាល់បង្ហាញ់ចរកំបាន ចេះរក្សាប្រើគេបង្រៀនឲ្យនៅជាមួយមនុស្សកោកះដោយគ្រោះថ្នាក់បាន មិនស្លូវចេះយកសត្វមកធ្វើជាអាហារបរិភោគទេ គ្រប់ទំហំនគរយើញហុង បក្សីដូចសេក សារិកា ក្ងោក ៗ ល ៗ នៅជិតមនុស្សគ្រប់គាល ៗ

ក្នុងសម័យព្រេងនាយ គមនាគមន៍ចេញទៅប្រទេសក្រៅមិនសម្បូរណ៍ទេ ព្រោះដែនដីប្រទេសនេះមានបត៌គធំ ៗ ជាកំពែងទៅព័ទ្ធជុំវិញ មានតែច្រកខ្លះនៅចុងបត៌គហិមាល័យខាងទិសបូព៌ទិងបស្ចិមប៉ុណ្ណោះ ៗ តាមជ្រលងមហានទីព្រហ្មបុត្រ

មានច្រកតូចចង្អៀតមួយចេញចូល សម្រាប់ធ្វើពាណិជ្ជកម្មជាមួយនឹងប្រទេសចិន ។ នេះទុកជាគមនាគមន៍ដ៏បរិតហិមាល័យ ខាងវិសហ្វូតិ ។ តាមជ្រលងបព៌តការ៉ាកោរ៉ម មានច្រកមួយចេញចូលបាន តែមិនសូវសំខាន់ទេ ។ ច្រកមួយគ្រាន់បើបន្តិច គឺច្រកចេញចូលតាមប្រទេសអ៊ីរ៉ង់ ហៅថាច្រកបព៌តម៉ាក្រាន (Makràn) ជាច្រកធំដែលព្រះបាទអាឡិចសង់ដ្រ៏មហាកងថយដៃហើយដកទ័ពថយចេញទៅ ។ ច្រកមួយទៀតចេញពីតំបន់សេអ៊ីស្ថាន (Seisthàn) កាត់កន្ទហារ (Kandahàr) ទៅពោឡាន (Bolàn) ។ គេអាចទៅមកបានខ្លះដែរតាមជ្រលងស្ទឹងគុរ៉ម (Kurram) និងគោមល (Gomal) ក្នុងច្រកទាំងនេះ ច្រកដែលសំខាន់ជាងគេ គឺច្រកខាងលើតំបន់កាប៊ូល (Kabul) ទៀតតាមស្ទឹងកាប៊ូលទៅកាន់ច្រកខៃបារ (Khaibàr) ច្រកនេះហើយដែលព្រះបាទអាឡិចសង់ដ្រ៏មហារាជ លើកព្យុហយាត្រាចូលលុកលុយយកប្រទេសឥណ្ឌា ។

នេះទុកជាគមនាគមន៍ចុងបព៌តហិមាល័យខាងទិសបស្ចិម ។

ឯគមនាគមន៍ក្នុងប្រទេស មិនមានឧបសគ្គធំដុំទេ សូម្បីឃាតបស្ចិមក៏មិនមែនជារនាំងធំដែរ គេអាចឆ្លងកាត់ទៅវិញទៅមកបាន ឯអារ្យធម៌ក៏ឆ្លងទៅមកតាមផ្លូវនេះដែរ ប្រែថាប្រទេសឥណ្ឌា មានឯកភាពខាងភូមិសាស្ត្រប្រសើរណាស់ រីឯកភាពខាងអារ្យធម៌ក៏ប្រសើរណាស់ដែរ ប៉ុន្តែគមនាគមន៍នេះ មិនត្រូវយល់ថាជាការងាយ ហើយទៅមកបានឆាប់ទាន់ចិត្តនោះទេ ។ រីទីហ៊ានកលឥណ្ឌូ-គង្គា ដែលបិតនៅចន្លោះបព៌តហិមាល័យនិងកលខ្សាច់ល្ហុល្ហៃថារ (Thar) ក៏ជាច្រកចង្អៀត តែជាផ្លូវពាណិជ្ជកម្មក៏បាន ជាផ្លូវសត្រូវខាងក្រៅចូលមកក៏បាន តាមច្រកនេះហើយដែលកើតមហាសង្គ្រាមពីបុរាណកាលក្នុងប្រវត្តិសាស្ត្រឥណ្ឌា ដូចជារឿងមហាភារត-យុទ្ធនៅកុរុក្សេត្រជាដើម ។ គមនាគមន៍នេះ មិនមែនមានធម្ម-ជាតិជាឧបសគ្គត្រឹមតែប៉ុណ្ណឹងទេ មានសត្រូវដទៃច្រើនទៀត

គឺទុរភិក្ស ភ័យខ្លាច ព្រៃញាតស្បាត សត្វសាហាវ ទុរគមន៍ ភ្លៀង ធ្លាក់ អាកាសធាតុ សត្វល្អិត ភយន្តរាយទាំងនេះ គួរសៀមណាស់ សូម្បីមេទ័ពហៅហានក៏ខ្លបខ្លាច ញញើតភ័យ ខ្លាចញាប់ញ័រខឹងខ្សល់ព្រុះព្រោមា ព្រៃស្ងាត់ ទុរគមន៍ មិនផុត មានតែចោរសាហាវយង់ឃ្នងនេះដែរ ៗ នេះហើយដែលលោកហៅថា "មហាកន្តារ" ជាឧបសគ្គធំបំផុតដល់បរន្តនៃកាយធម៌ បានជាអ្នកផងពោលទុកជាមេរៀនថា "ព្រៃស្តុកបក់កន្ទ្រៀនបច្ចិមប្រទេសនេះហើយ មិនមែនខ្ទិនភាពទឹកដីទេ ដែលញែកប្រទេសឥណ្ឌានេះជា ២ ផ្នែកឲ្យដាច់ចេញពីគ្នាគឺ ឥណ្ឌាកាយធម៌និងឥណ្ឌាត្រាវិឌ" មហាកន្តារនេះ មុខគួរឲ្យយើងសៀមពិតប្រាកដមែន ។

កាលពីព្រេងនាយ ប្រទេសឥណ្ឌានេះ មានតែផ្លូវធម្មតា យានជំនិះធម្មតា ការធ្វើដំណើរ មានការលំបាកច្រើនណាស់ យានជំនិះបុរាណគឺរទេះគោ ប្រើការដាក់លើខ្នងគោ លា ឧដ្ឋ

ដីរ. ដំណើរទៅមកយឺតយូរណាស់ ដោយផ្លូវប្រទេសជំហួស ពេក ហើយគេបានព្យាយាមកសាងគមនាគមន៍ក្នុងប្រទេសឲ្យ ជាប់គ្នាអស់កាលយូរហើយ ដូចវិស័យផ្សេងៗឯទៀតដែរ គឺ ផ្លូវធំមួយចេញពីប្រទេសអ៊ីរ៉ង់ទៅរដ្ឋបេង្គ័ល កាត់តាមបេសាវ៉រ (Peshewar) និងបត្ន (Patna) ចាប់កសាងតាំងពីរាជវង្ស មោរ្យ: (Maurya) និងរាជវង្សគុប្ត (Gupta) ហើយគេបាន ឲ្យនាមបញ្ញត្តិថា "រាជមាគ៌" (Rȧjmargȧ) ។ ផ្លូវនេះ មាន ជើមសាខាទៅក្នុងកោសម្ពី (Kauçambi) ចែកទៅក្រុងឧជ្ជេន និងមហាក្រុង ។ កាលរាជវង្សមុង់ហ្គោល (សេរសាហ៍ = Sër Sȧh គ.ស.១៥៤០) បានជួសជុលផ្លូវនេះឡើងវិញ សព្វថ្ងៃនេះ មុខងារគមនាគមន៍ផ្លូវនេះ បិទបើករហូតមកដល់ឥឡូវ ហើយក្នុងពេល អង់គ្លេស គេបានកែលម្អមកទៀត ព្រមទាំងបានសាងផ្លូវថ ភ្លើងមួយខ្សែធំ ដាក់ឈ្មោះនេះហៅថាផ្លូវ "បញ្ចាប-ម៉ែល" (Puniȧb-mail) ពីក្រុងកាលកុត្តាទៅបេសាវ៉រទៀត ។ ក្នុងបច្ចុប្បន្ន

កាលនេះ ប្រទេសរ៉ូមទើបបានធ្វើគមនាគមន៍ឥណ្ឌា ឲ្យ ចម្រើនវិសេស ប៉ែកជាងសម័យព្រេងនាយឆ្ងាយណាស់ មាន អយស្ម័យយាន ទូកលេង យានយន្តគ្រប់ជំពូក ដែលជាមធ្យោ-បាយដ៏ប្រសើរនៃប្រជាជាតិមួយក្នុងលោក ។ ឯអយស្ម័យ-យានឥណ្ឌា បានឡើងដល់ថ្នាក់ទី ៣ ក្នុងលោក បន្ទាប់ពី ប្រទេសអាមេរិកាំងនិងរុស្ស៊ី ។

គមនាគមន៍តាមសមុទ្រ ជនឥណ្ឌាចេញទៅឆ្ងាយ តែ មិនសូវចេញទៅទាក់ទងប្រទេសទេ ច្រើនទៅខាងបូព៌ាប្រ-ទេស ទៅកោះលង្កា កោះជ្វា ដែលគេហៅថាសុវណ្ណទ្វីបនិង ទៅសុវណ្ណភូមិ បានដល់ប្រទេសអាស៊ីអាគ្នេយ៍ទាំងអស់ ។ ការធ្វើដំណើរក្នុងប្រទេសកាលនោះយឺតយូរណាស់ ចំពោះតែទៅ មកដល់ចុងបំផុតខាងត្បូង គឺពីរាមេស្វរ៉ម (Ràmecyaram) ទៅឡាហ័រ (Lahore) មួយឆ្នាំគត់ ទើបដល់ទៅវិញទៅមក តែបើតាមផ្លូវសមុទ្រចេញទៅប្រទេសក្រៅវិញ ជុំយគ្នាស្រួលៈ

មិនយឺតយូរពេកទេ ទៅកោះជ្វាត្រឹមតែមួយថ្ងៃ បើទៅប្រទេស ខ្មែរសម័យអង្គរត្រឹមតែពីរបីថ្ងៃ ទៅមកដល់គ្នាហើយ ៗ នេះ ជាហេតុការណ៍ដើមចមគន្ទុប្រវត្តិសាស្ត្រនៃកាយធម៌ ។

និយាយដូចម្តេចទៅឲ្យបានសមហ៊ា::? នៅប្រទេសណាក្តី នេះ មិនគឺប្រទេសដទៃទេ ដែលមនុស្សលោកសម្រេចចិត្តថា ត្រូវតែគស្ញូចំពោះធម្មជាតិដ៏រឹងនេះយកឈ្នះឡើងបាន ៗ ស្នាដៃ ដ៏ធំមហិមានេះ បើលោកទៅយកដូចជាមនុស្សលោកបានធ្វើកតិ-កាសញ្ញាជាមួយធម្មជាតិ គឺសន្ធិសញ្ញាមួយដែលមានលក្ខណៈ កើតឡើងពីគំនិតតែខ្លួន ៗ វីធម្មជាតិមហាភូតរូប ទឹកដីដី សម្បើមអស្ចារ្យប្រាកដដូច្នេះ មិនមែនមិនធ្វើឲ្យមនុស្សលោក ផុសគំនិតកើតប្រាជ្ញា ធ្វើមនសិការប៉ុនម៉ាត់ ព្រមទាំងធ្វើឲ្យ កើតបរមាសព្វគតា ដោយក្តីមាន.ដែលកើតពីមនុស្សជាតិ ជាត្រូវយកជាញជ័យឲ្យទាល់តែបាន ចំពោះគេជាខុភាពមហា ភូតរូបដ៏រឹងពោលគឺ ទឹក ដី ភ្លើងខ្យល់ ដែលមិនមានទីបំផុត

និងប្រមាណមិនបាននេះទេ ថ្វីត្បិតតែរូបមនុស្សមាឌតូចល្អិត កញ្ច្រឹកដូច្នេះ ៗ មហាកូតរូបបែបនេះ ជាអ្នកឲ្យកំណើតមេលទ្ធិ មហាសមា មេទ្រឹស្ដី មេមិការ មេវិជ្ជា ល្បីល្បាញខ្ចរខ្ចាយខ្ទរទៅក្នុងពិភពលោក លើកប្រទេសនេះឲ្យមានកិត្តិនាមថា ជាប្រទេសជាន់ឯកមានបេសាយ៍ធំ ៗ

ប្រទេសឥណ្ឌា មានទំហំដីប្រមាណ ៤.១៨០.:០០ គីឡូម៉ែត្រការេ មានភូមិ ៧០០.០០០ ភូមិ មានប្រជាជន ៤០០ លាននាក់ មានកុលសម្ពន្ធផ្សេងគ្នា មានភាសា ៧៤៨ ផ្សេងគ្នា អក្សរផ្សេងគ្នា ប្រទេសធំមានប្រជាជនច្រើនដល់ម្ល៉េះ ក្ដីណាស់តែការទាក់ទងគ្នាកើតជាឧបសគ្គ នាំមិនឲ្យរួមគ្នាបានដោយប្រពៃតែស្រេចក្ដីពិត ជួយគ្នាទៅវិញ ប្រទេសឥណ្ឌាមានឯកភាពជាក់ស្ដែងបំផុតគួរឲ្យកត់សំគាល់ ថ្វីត្បិតតែក្រុងធំ ១ បែកនៅឆ្ងាយពីគ្នា តែភូមិ ទាំង ៧០០.០០០ នេះ បែកនៅជាប់គ្នា ដែលជាដើមចមនាំឲ្យមានឯកភាពខាង ជំនឿសាសនា ខាង

ទំនៀមទម្លាប់ ខាងពាក្យសព្ទរួមគ្នា ដោយមិនដាច់ចាំមានឯក-ភាពខាងការរដ្ឋនិងខាងភាសាជាតិតែមួយរួមគ្នាឡើយ ផ្ទុយគ្នាស្រឡះពីហេតុការណ៍នៃប្រទេសចិន ដែលជាប្រទេសធំដូចគ្នា តែមានឯកភាពខាងរដ្ឋខាងអក្សរខាងកាលប្បវត្តិជារួមគ្នាៗ

ឯជនជាតិខ្មែរ ដែលធ្លាប់នៅប្រទេសកូប មានប្រជាជនតិច មានអាហារគោជនបរិបូណ៌ ទឹកដីស្ដុក មិនកាចពេក មិនរឹងពេក អាកាសធាតុល្មម មិនក្តៅពេក មិនត្រជាក់ពេក បើចូលមកដល់ប្រទេសឥណ្ឌា ហើយមើលទៅឃើញទឹកដីធំល្វឹងល្វើយ មហានទីហូរខ្វាញ់ បព៌តហេមពាន្តធំមហិមា ខ្ពស់ស្កឹមស្កៃ កំពូលសក្បុសដោយទឹកកក បព៌តវិទ្យុខ្ពស់ត្រដូចត្រដឹម ព្រៃញាក់ស្យាក់ចុំតម វាលខ្សាច់ធំធេងមិនធំ មើលទៅដាច់កន្ទុយភ្នែក ឃើញតែមេឃ ក្រុងធំ ៗ ដូចក្រុងកាលកុត្តា ក្រុងបុំបៃយ មានប្រជាជនរាប់លាន ៗ កកស្រទាប់គ្នា នៅទាំងហ្វូងមកទាំងហ្វូង អាកាសធាតុឃោរឃៅ ក្តៅក៏ក្តៅអនេក

អនន្ត ត្រជាក់ ក៏ត្រជាក់ស្រេប សត្វបើត្រាទ់តែក្តៅត្រជាក់ក៏ មនុស្សស្លាប់ដែរ, មើលទៅដូចជាវេទ្ធិកណ្ដាលអគ្គាជីធំថប់ ដូចគេឲ្យលំផកដង្ហើមគ្មាន ដេកមិនលក់ចក់មិនរ ហើយ ស៊ីមិនបាន ប្រះប្រាណមិនស្រណុក ទឹកទៅដល់ស្រុកខ្លួន ដែលតូចហើយស្អាត សម្បូណ៌ មិនសូវមានភ័យបារម្ភពីធម្មជាតិ ទឹកដីគម្រោបទ្រៀយ ។

---

# អារ្យធម៌ខ្មែរ

## សេចក្ដីផ្ដើម

ក្នុងលោកនេះ ឬក្នុងលោកដទៃទៀត តែងមានធម្មជាតិ ៤ ប្រការដែលជាប់តពាក់ព័ន្ធគ្នា ដូចច្រវាក់មិនញែកចេញពីគ្នាពុំបាន ។ ធម្មជាតិ ៤ ប្រការនេះគឺ

- ការកើត
- ការចំរើនឡើង ឬ ឧទ្ធង្គត
- ការឱនថយទៅវិញ
- ការរលត់សូន្យទៅវិញ ឬអត្ថង្គត

តាមផ្លូវប្រវត្តិសាស្ត្រ យើងឃើញថាការប្រព្រឹត្តទៅនៃមនុស្សជាតិ រមែងរត់មិនរួចពីគោល ៤ ប្រការនេះបានឡើយ

ពោលគឺ កើតឡើង ចំរើនឡើង ទុនថយទៅ រលត់សូន្យទៅ ជាទីបំផុត ។ ការអស់នេះ តែងកើតមានជាប់រហូតមក ។ ប្រជាជាតិណាមួយ ដែលបានទទួលក្តីចំរើនក្រៃលែង មានអំណាចធំពិសាល ដូចជាប្រទេសខ្មែរយើងសម័យមហានគរ ក៏រលត់សាបសូន្យទៅវិញក្នុងវេលានេះ ។

សេចក្តីពិត ធម្មជាតិ ៤ នេះ បើពុំគង់ជាប់ទាក់ទងគ្នាជាលំដាប់ទៅ ទើបជាលាយហេតុផលនៃគ្នានិងគ្នា ក៏ឥតអ្វីមានឡើយ ។ មនុស្សយើងកើតមកហើយ ក៏ត្រូវតែចំរើនឡើង កាលបើធំចំរើនឡើងហើយ ក៏ត្រូវតែចាស់ទ្រុឌទ្រោមទៅវិញ ទីបំផុតក៏ត្រូវស្លាប់ តែការកើត ការធំចំរើនឡើង ការចាស់ជរា និង ការស្លាប់ទៅវិញទាំងអស់នេះ សុទ្ធតែជាផលដែលមានជាប់គ្នា ទើបជាអ្នកជាហេតុនៃអ្នកពុំទាន់គ្រប់ត្រូវ ដូចជាការកើត ជាហេតុនៃការចាស់ជរា ហើយការចាស់ជរា ជាហេតុនៃសេចក្តីស្លាប់ ដូច្នេះគឺមិនត្រូវពិតប្រាកដដែរ ព្រោះ